មិនអាចឱ្យខ្ញុំឈប់បំពេញករណីយកិច្ចនេះបានដែរ ។ ដូច្នេះខ្ញុំសូមអង្វរលោកតាម្តងទៀត សុំឱ្យលោកតាប្រាប់ខ្ញុំភ្លាមមក ហើយសុំកុំប្រកែកនឹងសេចក្តីអង្វរខ្ញុំនេះទៀតឱ្យសោះ ។

អ្នកបួសកាលបើសម្គាល់ឃើញថា គាត់ពុំអាចរាំងរាបំណងព្រះអង្គម្ចាស់បានទេ ព្រោះព្រះអង្គនៅតែចចេសរឹងចង់តែយាងទៅកន្លែងនោះ ថ្វីបើគាត់ខំឱ្យដំបូន្មានដែលអាចជួយស្រោចស្រង់ជីវិតបានក៏ដោយ, ក៏លូកដៃយកដុំមូលមួយនៅក្នុងថង់ជិតគាត់នោះ ហើយថ្វាយទៅព្រះអង្គម្ចាស់បាម៉ានដោយពោលដូច្នេះថា : "ព្រោះខ្ញុំពុំអាចនិយាយឃាត់លោកម្ចាស់បាន, សូមលោកម្ចាស់ចាំស្តាប់ខ្ញុំ ហើយទាញយកប្រយោជន៍ពីដំបូន្មានខ្ញុំនេះចុះ សូមលោកម្ចាស់កាន់ដុំមូលនេះឡើង រួចកាលបើលោកម្ចាស់ឡើងជិះលើសេះរួចហើយ, សូមបោះដុំមូលនេះទៅមុខលោកម្ចាស់ ហើយបរសេះតាមរបស់នេះឱ្យជាប់ លុះត្រាទៅដល់ជើងភ្នំមួយដែលវាត្រូវឈប់" ។ កាលបើដុំនេះឈប់ហើយសូមលោកម្ចាស់ចុះពីខ្នងសេះ ហើយទុកសេះនៅទីនោះចុះ គ្រាន់តែត្រូវយកខ្សែបង្ហៀដាក់លើកវាប៉ុណ្ណោះ សេះនេះនឹងឥតដើរទៅណាបានឡើយ វានឹងនៅឈរចាំលុះត្រាលោកម្ចាស់ត្រឡប់មកវិញ ។ នៅពេលដែលលោកម្ចាស់ដើរឡើងភ្នំនោះទៅ លោកម្ចាស់នឹងបានឃើញនៅខាងស្តាំនិងខាងឆ្វេងដៃ ដុំថ្មពណ៌ខ្មៅជាច្រើនអនេក, ហើយលោកម្ចាស់នឹងបានឮសម្លេងទ្រហឹងអឺងកងច្របូកច្របល់គ្នាពីគ្រប់ទិសទី



ទាំងអស់ ។ គឺជាសម្លេងស្រែកជេរប្រទេចផ្តាសាលោកម្ចាស់ឱ្យលោកម្ចាស់នឿយណាយធុញទ្រាន់ ខូចទឹកចិត្ត កុំឱ្យលោកម្ចាស់ឡើងទៅដល់លើកំពូលភ្នំបាន ។ ប៉ុន្តែសូមលោកម្ចាស់ប្រយ័ត្នឱ្យមែនទែន កុំខ្លាចឱ្យសោះហើយជាពិសេសគឺកុំងាកបែរមើលក្រោយ ។ បើសិនជាលោកម្ចាស់ងាកបែរមើលក្រោយ, នោះលោកម្ចាស់នឹងក្លាយទៅជាថ្មខ្មៅមួយរំពេច ដូចជាពួកសេដ្ឋីឬអភិជនឯទៀត ដែលលោកម្ចាស់បានឃើញនោះ ព្រោះដុំថ្មខ្មៅទាំងនោះជាពួកអភិជនដូចជាលោកម្ចាស់ដែរ ដែលប្រតិបត្តិការណ៍ពុំបានសម្រេចដូចបំណង ដូចខ្ញុំបាននិយាយជម្រាបលោកម្ចាស់រួចមកហើយ ។ បើសិនជាលោកម្ចាស់អាចជៀសគ្រោះថ្នាក់ ដែលខ្ញុំគ្រាន់តែបាននិយាយជម្រាបសើៗប៉ុណ្ណេះបាន ដើម្បីឱ្យលោកម្ចាស់ទ្រង់ពិចារណាមើល ។ កាលបើលោកម្ចាស់បានឡើងទៅដល់លើកំពូលភ្នំ លោកម្ចាស់នឹងបានឃើញទ្រុងមួយនៅទីនោះ គឺនៅក្នុងទ្រុងនោះហើយ ដែលគេដាក់បក្សាចេះនិយាយ ។ ដោយហេតុថា សត្វបក្សានោះចេះនិយាយ សូមលោកម្ចាស់សួរវាទៅ អំពីទីកន្លែងដើមឈើចេះច្រៀង និងទឹកពណ៌លឿង, វានឹងប្រាប់លោកម្ចាស់ពុំខានខ្ញុំគ្មានអ្វីនឹងជម្រាបលោកម្ចាស់ក្រៅពីនេះទៀតទេ។ នេះហើយជាកិច្ចដែលលោកម្ចាស់ត្រូវធ្វើ និងនេះហើយជាការដែលលោកម្ចាស់ត្រូវជៀសវាង ។ ប៉ុន្តែបើសិនជាលោកម្ចាស់ជឿតាមខ្ញុំ ហើយធ្វើតាមដំបូន្មានខ្ញុំនេះ, នោះលោកម្ចាស់ឥតបារម្ភនឹងក្ស័យជីវិតឡើយ ។ ដូច្នេះ

ខ្ញុំសូមជម្រាបម្ដងទៀតថា. ទាន់ឱកាសនៅមាននឹងពិចារណា សូមលោកម្ចាស់មេត្តាសញ្ជឹងត្រិះរិះឱ្យមែនទែន ព្រោះការបាត់បង់ជីវិតនេះគ្មានអ្វីជួសជុលបានទេ ហើយស្ថិតនៅជាប់នឹងលក្ខខណ្ឌដែលគេប្រព្រឹត្តល្មើស ឬក៏ការធ្វេសប្រហែស. សូមលោកម្ចាស់យល់ឱ្យច្បាស់ ។

ព្រះអង្គម្ចាស់បាម៉ាន ក្រោយពីបានទទួលដុំមូលពីអ្នកបួសហើយ ក៏មានព្រះបន្ទូលថា : "ចំពោះដំបូន្មានដែលលោកតាបានទូន្មានហើយទូន្មានទៀតនេះ ហើយដែលខ្ញុំត្រូវតែនឹកគុណលោកតាឥតភ្លេចនោះ. ខ្ញុំពុំអាចធ្វើតាមបានទេ. ប៉ុន្តែខ្ញុំនឹងខិតខំឆ្លៀតយកប្រយោជន៍អំពីដំបូន្មានដែលលោកតាបានហាមខ្ញុំកុំឱ្យងាកក្រោយ នៅពេលដើរឡើងទៅ ហើយខ្ញុំសង្ឃឹមថា មិនយូរប៉ុន្មានលោកនឹងឃើញខ្ញុំត្រឡប់មកវិញ ហើយមកសម្ដែងអំណរគុណដ៏ជ្រាលជ្រៅដល់លោកតា ដោយបានទាំងរបស់នោះមកជាមួយផង" ។ កាលបើមានព្រះបន្ទូលដូច្នេះចប់កាលណា ព្រះអង្គម្ចាស់ក៏ឡើងគង់សេះជម្រាបលាអ្នកបួស ដោយអោនព្រះកេសគោរពយ៉ាងគួរសមបំផុត រួចក៏បោះដុំមូលនោះទៅមុខព្រះអង្គ ។

ដុំមូលនោះបានរមៀល ហើយចេះតែរមៀលទៅមុខជានិច្ចដោយល្បឿនដដែល តាមល្បឿនដើមដែលព្រះអង្គម្ចាស់បានបោះទៅ ។ ដូច្នេះ ព្រះអង្គម្ចាស់បរសេះតាមនៃល្បឿន. ឱ្យត្រូវនឹងល្បឿនដុំមូលនោះ ដើម្បីកុំឱ្យបាត់ព្រះនេត្រពីដុំមូល ។ កាលបើទៅដល់ជើងភ្នំដែល



អ្នកបួសបាននិយាយ ដុំមូលនៅក៏ឈប់ស្ងៀម ។ ព្រះអង្គម្ចាស់ក៏យាងចុះពីខ្នងសេះ យកខ្សែបង្ហៀដាក់ទៅលើកវា សេះក៏ឥតមានដើរទៅណាចោលកន្លែងឡើយ ។ បន្ទាប់ពីបានពិនិត្យមើលភ្នំ. នឹងសម្គាល់ឃើញដុំថ្មខ្មៅៗនោះ ហើយព្រះអង្គម្ចាស់ក៏ចាប់យាងឡើងទៅលើភ្នំ ។ ទ្រង់យាងឡើងពុំទាន់តែបានគ្រប់បួនជំហានផង. សម្លេងដែលអ្នកបួសបាននិយាយនោះ បានលាន់ឮឡើងរំពងអឺងកង តែឥតឃើញមានមនុស្សម្នាណាម្នាក់ ។ អ្នកខ្លះពោលថា : "តើមនុស្សពញ្ញើនេះទៅណាមកណា? វាចង់បានអ្វី? ចូរកុំឱ្យវាទៅ" ។ ខ្លះទៀតពោលដូច្នេះ : "ចាប់វាឱ្យជាប់. យកវាមក. សម្លាប់វាចោលទៅ" ខ្លះស្រែកឮដូចផ្គរលាន់ : "ចោរ ! មនុស្សឃាដ ! មនុស្សធ្វើអំពើឃាដកម្ម !" ខ្លះផ្ទុយទៅវិញស្រែកចំអកឡកឡឺយថា: "ទេ. កុំធ្វើបាបគាត់. បើកផ្លូវឱ្យបងកំលោះគាត់ទៅផង គឺគាត់នេះហើយដែលគេត្រូវទុកទ្រុងនឹងបក្សាជូន !" ។

ថ្វីបើឮសម្រែកបៀតបៀនរំខានដូច្នោះក៏ដោយ. ក៏ព្រះអង្គម្ចាស់បាម៉ាន នៅតែខំយាងឡើងទៅបានមួយសន្ទុះ ដោយសភាពនឹងនួនយ៉ាងអង់អាច ប៉ុន្តែសម្លេងចេះតែផ្ទួនឡើងៗលាន់សូរជាខ្លាំង. ហើយនៅជិតៗព្រះអង្គម្ចាស់ផង ខ្លះពីមុខខ្លះពីក្រោយ លុះគ្រាតែព្រះអង្គកើតសេចក្ដីខ្លាចឡើងញ័រព្រះហស្ដព្រះបាទទាំងអស់. ទើបទ្រង់មានដំណើរទៅជាទ្រេតទ្រោត ។ រួចកាលបើព្រះអង្គម្ចាស់យល់ថា.

ទ្រង់អស់កម្លាំងកាន់តែខ្លាំងណាស់ហើយ ទ្រង់ក៏ភ្លេចនឹកដល់បណ្តាំអ្នកបួសឈឹង. ហើយទ្រង់ងាកបែរទៅក្រោយដើម្បីរត់ចុះទៅវិញ ប៉ុន្តែពុទ្ធោអើយមួយរំពេចនោះ ព្រះអង្គម្ចាស់ទ្រង់ក្លាយទៅជាថ្មខ្មៅភ្លាម ការផ្លាស់រូបរាងនេះ បានកើតមានឡើងដល់ជនជាច្រើនមុនព្រះអង្គដែលមានបំណងដូចគ្នានេះ ។ មិនតែប៉ុណ្ណោះ សត្វសេះក៏ត្រូវទទួលការផ្លាស់ជាតិនេះដែរ ។

ចាប់តាំងពីព្រះអង្គម្ចាស់បាម៉ានបានធ្វើដំណើរយាងចេញទៅ ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ឥតដែលខាននឹងហូតកាំបិត ដែលព្រះអង្គម្ចាស់ព្រះរៀមបានទុកថ្វាយមើលក្នុងមួយថ្ងៃៗជាច្រើនដង ប្រយោជន៍ឱ្យបានដឹងថា តើព្រះរៀមមានព្រះជន្មគង់នៅទេ ឬក៏អស់ព្រះជន្មហើយ ។ ព្រះនាងបានចងកាំបិតនេះជាប់នឹងខ្សែក្រវាត់ព្រះនាងជាមួយនឹងស្រោម ។ អាស្រ័យដោយហេតុដូច្នេះ. ព្រះនាងក៏បានស្រាកស្រាន្តទុក្ខម្តងៗ ដោយបានដឹងថាព្រះរៀមទ្រង់សុខសប្បាយព្រះអង្គទេ ហើយព្រះនាងតែងបានយករឿងព្រះអង្គម្ចាស់ព្រះរៀមមកសន្ទនាជាញឹកញយជាមួយនឹងព្រះអង្គម្ចាស់ប៉ៃវិស ដែលទ្រង់តែងបានសួរព្រះនាងជាញយៗដែរ អំពីដំណើរព្រះអង្គម្ចាស់ព្រះរៀម ។

លុះមកដល់ថ្ងៃចង្រៃដែលព្រះអង្គម្ចាស់ព្រះរៀមត្រូវក្លាយព្រះអង្គទៅជាថ្មខ្មៅ. នៅវេលាល្ងាចព្រះអង្គម្ចាស់ក្សត្រីនឹងព្រះអង្គម្ចាស់ប៉ៃវិសទ្រង់បានសន្ទនាគ្នាពីរឿងព្រះអង្គម្ចាស់ព្រះរៀមតាមទម្លាប់រៀង



មក ព្រះអង្គម្ចាស់ប៉ៃវិសមានព្រះបន្ទូលថា : “ម្ចាស់ក្សត្រីអូន. សូមម្ចាស់អូនហូតកាំបិតមើល ហើយយើងនឹងបានដំណឹងយ៉ាងណាទៀត” ។ ព្រះអង្គម្ចាស់ក្សត្រីក៏បានហូតកាំបិតចេញមក. ហើយទាំងពីរព្រះអង្គទ្រង់ទតទៅឃើញស្រក់ឈាមនៅចុងកាំបិត ។ ទើបព្រះអង្គម្ចាស់ក្សត្រីយល់នូវភេវរកម្មនិងការឈឺចាប់ដូច្នេះ ក៏គ្រវែងកាំបិតនោះចោល រួចទ្រង់ស្រែកយ៉ាងភ្លាត់សម្លេងថា : “អីយ៉ា ! ម្ចាស់ព្រះរៀម. ម្ចាស់ព្រះរៀមចាកចោលម្ចាស់អូនហើយឬ ចាកចោលម្ចាស់អូនបណ្តាលមកពីកំហុសម្ចាស់អូន ! ម្ចាស់អូនខានឃើញព្រះភក្ត្រព្រះរៀមទៀតហើយ! តើខ្ញុំជាមនុស្សកំណាចយ៉ាងណាទៅ? ហេតុអ្វីក៏ខ្ញុំនិយាយរឿងបក្សាចេះនិយាយ. ដើមឈើចេះច្រៀង និងទឹកពណ៌លឿងប្រាប់ព្រះអង្គ ។ ហើយម្យ៉ាងទៀត តើហេតុអ្វីបានជាខ្ញុំចាំបាច់ត្រូវការសួរស្រីអ្នកកាន់សាសនាអ៊ីស្លាមថាផ្ទះនេះល្អឬអាក្រក់ មានវត្ថុតាំងគ្រប់គ្រាន់ហើយឬនៅ? ឱទេវតាអើយ ចុះហេតុអ្វីក៏គាត់មិនប្រាប់ពីរឿងគ្រោះថ្នាក់នេះផង ! ស្រីលាក់ពុត ស្រីឆបោក ម្តេចក៏អ្នកមិននឹកដល់គុណដែលខ្ញុំបានធ្វើបដិសណ្ឋារកិច្ចដល់អ្នកផង? ហេតុអ្វីក៏អ្នកបាននិយាយប្រាប់ខ្ញុំអំពីបក្សា អំពីដើមឈើ. អំពីទឹក ដែលជារបស់មាននៅតែក្នុងមនោគតិ ហើយធ្វើឱ្យខ្ញុំជឿ លុះគ្រាតែត្រូវស្លាប់បងជាទីស្នេហារបស់ខ្ញុំបាត់ទៅដូច្នេះ ហើយរបស់ទាំងនោះនៅតែមករំខានខួរក្បាលខ្ញុំឱ្យគិតនឹកដល់ដោយសារអំពើស្នេហ៍របស់អ្នក?” ។

ព្រះអង្គម្ចាស់ប៉ៃរិស ក៏ទ្រង់កើតទុក្ខជាពន់ប្រមាណក្នុងរឿង
នេះ ដូចជាព្រះអនុជក្សត្រីដែរ ប៉ុន្តែព្រះអង្គឥតនៅបង្អង់ឱ្យខាតពេល
វេលាតែកើតទុក្ខសោកស្ដាយឥតអំពើនោះទេ ដោយហេតុថា ព្រះអង្គ
ម្ចាស់ទ្រង់យល់នូវព្រះទ័យម្ចាស់អូននៅតែលោភលន់ពន់ប្រមាណ ចង់
បានបក្សាចេះនិយាយ ដើមឈើចេះច្រៀងនិងទឹកពណ៌លឿង ព្រះអង្គ
ម្ចាស់ក៏មានព្រះបន្ទូលឡើងថា : "ម្ចាស់ក្សត្រីអូន. យើងនឹងនៅស្រ-
ណោះអាឡោះសោកស្ដាយម្ចាស់ព្រះរៀមយើងដូច្នេះ ក៏ជាការឥត
អំពើដែរ ។ សេចក្ដីតូញត្អែរ កើតទុក្ខរៀបរាប់របស់យើងនេះមិនអាច
ញ៉ាំងឱ្យម្ចាស់ព្រះរៀមមានព្រះជន្មាយុឡើងវិញទេ គឺជាឆន្ទៈព្រះអា-
ទិទេព ។ យើងត្រូវតែចុះចូលធ្វើតាមឆន្ទៈនេះ ហើយគោរពតាម
សេចក្ដីសម្រេចចិត្តរបស់ព្រះអង្គ មិនត្រូវមានចិត្តចង់ជ្រៀតជ្រែកចូល
ក្នុងរឿងនោះឡើយ ។ ចុះហេតុអ្វីបានជាអម្បាញ់មិញ ម្ចាស់អូនមិន
ចង់ជឿតាមសម្ដីអ្នកស្រីកាន់សាសនាអ៊ីស្លាម បន្ទាប់ពីម្ចាស់អូនបាន
សម្គាល់យ៉ាងម៉ឺងម៉ាត់ក្នុងចិត្តថា ជាការពិតហើយច្បាស់ណាស់នោះ?
ម្ចាស់អូនស្មានថា តើគាត់អាចនិយាយប្រាប់ម្ចាស់អូនអំពីរបស់បីយ៉ាង
នោះបានទេ. បើសិនជារបស់នោះគ្មានសោះ ហើយគាត់ទើបតែនឹង
ប្រឌិតឡើងដោយចេតនា ដើម្បីនឹងបញ្ឆោតម្ចាស់អូនដែលបានធ្វើ
បដិសណ្ឋារកិច្ចទទួលគាត់ ដោយរីករាយនិងដោយសប្បុរស? មួយ
ចំណែកទៀត តើយើងអាចជឿថា ការសោយទីវង្គតនៃម្ចាស់ព្រះរៀម



យើង បណ្ដាលមកពីកំហុសគាត់ ឬក៏បណ្ដាលមកពីគ្រោះថ្នាក់ផ្សេងៗ
ដែលយើងពុំអាចស្មានបាន? ដូច្នេះ ម្ចាស់ក្សត្រីអូន ដោយការសោយ
ទីវង្គតរបស់ព្រះរៀមឥតជាឧបសគ្គអ្វីដល់ខ្ញុំនឹងបន្តការស្វែងរករបស់
ម្ចាស់អូនទេនោះៗ ខ្ញុំសុំខ្លួនចេញធ្វើដំណើរស្វែងរកនេះស្នងព្រះរៀម.
ខ្ញុំក៏មានបំណងដូចជាព្រះអង្គដែរ ទោះបីព្រះអង្គបានទទួលទុក្ខជាតំរូ
មកដូច្នេះក៏ដោយ. ក៏ខ្ញុំឥតផ្លាស់មនោសញ្ចេតនាឡើយ. ដូច្នេះនៅថ្ងៃ
ស្អែកនេះ ខ្ញុំនឹងចេញដំណើរទៅហើយ" ។

ព្រះអង្គម្ចាស់ក្សត្រីបានខំរករឿងនិយាយឃាត់ព្រះអង្គម្ចាស់
ប៉ៃរិសណាស់ ព្រមទាំងបានអង្វរព្រះអង្គកុំឱ្យយាងទៅរងគ្រោះថ្នាក់
ក្រែងមិនសុគតតែមួយព្រះអង្គទៅជាពីរព្រះអង្គទៅវិញ ប៉ុន្តែព្រះអង្គ
ម្ចាស់មិនព្រមតាមឡើយ ថ្វីបើព្រះនាងបានបំភ្លឺដូច្នេះក៏ដោយ ។ មុន
នឹងធ្វើដំណើរយាងចេញទៅ. ព្រះអង្គម្ចាស់បានថ្វាយចង្កោមគជ់មួយ
មាន ១០០ គ្រាប់ទៅព្រះនាង ប្រយោជន៍ឱ្យព្រះនាងអាចជ្រាបដំណឹង
អំពីលទ្ធផលនៃដំណើររបស់ព្រះអង្គ ដូចជាកាំបិតដែលព្រះអង្គម្ចាស់
ព្រះរៀមបានទុកថ្វាយព្រះនាងដែរ នៅពេលដែលព្រះអង្គយាងចេញ
ទៅ ។ នៅពេលថ្វាយចង្កោមគជ់នេះទៅព្រះនាង ព្រះអង្គម្ចាស់ប៉ៃរិស
ទ្រង់មានព្រះបន្ទូលថា : "នៅពេលដែលខ្ញុំមិននៅ សូមម្ចាស់អូននិ-
យាយសួរទៅចង្កោមគជ់នេះ ដើម្បីឱ្យដឹងដំណឹងពីខ្ញុំ។ កាលបើនិយាយ
ទៅហើយ. ឃើញគ្រាប់គជ់នោះឈប់ស្ងៀមហាក់ដូចជាផ្សារជាប់គ្នា

ទាល់តែម្ចាស់អូនពុំអាចធ្វើឱ្យកំរើកឬធ្វើឱ្យរមៀលតាមគ្នាបាន. សញ្ញានោះប្រាប់ឱ្យដឹងថា ខ្ញុំត្រូវបានទទួលវាសនាដូចជាម្ចាស់ព្រះរៀមដែរ ។ ប៉ុន្តែ សូមយើងសង្ឃឹមថា ការនេះនឹងឥតកើតមានឡើយ ហើយខ្ញុំប្រាកដជាមានវាសនាបានមកឃើញម្ចាស់អូនវិញ ដោយសេចក្តីរីករាយដែលយើងខំរង់ចាំមក" ។

ព្រះអង្គម្ចាស់ប៉ៃវិសក៏យាងចេញទៅ ហើយនៅថ្ងៃទីម្តេមួយ ព្រះអង្គក៏បានជួបនឹងអ្នកបួសដដែលនោះ នៅកន្លែងតែមួយដែលព្រះអង្គម្ចាស់បាម៉ានទ្រង់បានជួបពីមុន។ ព្រះអង្គម្ចាស់ក៏យាងចូលទៅជិតគាត់ គំនាប់គាត់គួរសមគាត់រួចហើយអង្វរសុំឱ្យគាត់បង្ហាញកន្លែង. បើសិនជាគាត់ដឹង. គឺកន្លែងបក្សាចេះនិយាយ. ដើមឈើចេះច្រៀង និងទឹកពណ៌លឿង ។ អ្នកបួសក៏មិនព្រមប្រាប់ព្រះអង្គសោះ ហើយគាត់បាននិយាយបំភ្លឺព្រះអង្គតាមហេតុផ្សេង ដូចជាគាត់បាននិយាយទូលព្រះអង្គម្ចាស់បាម៉ានដូច្នោះដែរ រហូតដល់ទៅនិយាយថា ទើបតែមិនយូរប៉ុន្មានផងនេះ មានអ្នកជិះសេះកំលោះម្នាក់ដែលមានទម្រង់រាងរៅស្រដៀងនឹងព្រះអង្គដែរនោះ បានមកសុំឱ្យគាត់បង្ហាញផ្លូវដូច្នេះដែរ ។ លុះចាញ់ចំណេះនិយាយហាមជននោះកុំឱ្យប្រាថ្នាដូច្នោះពុំស្តាប់សោះ. គាត់ក៏ព្រមបង្ហាញផ្លូវ. ឱ្យដុំមូលមួយសម្រាប់ធ្វើជាអ្នកមគ្គុទ្ទេសក៍ នឹងប្រាប់អំពីកិច្ចការផ្សេងៗដែលត្រូវកត់ចំណាំ ដើម្បីធ្វើការឱ្យបានសម្រេចតាមបំណង ។ ប៉ុន្តែ គាត់ឥតបានឃើញជននោះត្រឡប់



មកវិញសោះ។ ការនោះគ្មានសង្ស័យទេ គឺបុរសនោះត្រូវទទួលវាសនាដូចជាជនមុនៗដែរ ។

ព្រះអង្គម្ចាស់ប៉ៃវិសក៏មានព្រះបន្ទូលថា : "ជម្រាបអ្នកបួស. ខ្ញុំស្គាល់ហើយជនដែលអ្នកបានពោលនេះ គឺជាបងប្រុសច្បងបង្អស់របស់ខ្ញុំ ហើយខ្ញុំបានដឹងយ៉ាងពិតប្រាកដថាគាត់ស្លាប់ហើយ ប៉ុន្តែខ្ញុំពុំដឹងថា តើគាត់ស្លាប់ទៅកើតជាអ្វី" ។

- ខ្ញុំអាចជម្រាបលោកបាន. អ្នកបួសឆ្លើយ. គាត់បានផ្លាស់ជាតិទៅជាថ្មខ្មៅ ដូចជនឯទៀតដែលខ្ញុំបាននិយាយជម្រាបលោកដែរ ហើយលោកក៏ប្រហែលជានឹងត្រូវទទួលការផ្លាស់ជាតិដូចគ្នានេះដែរ ខណៈណាលោកមិនបានពិនិត្យឱ្យម៉ត់ចត់នូវដំបូន្មានទាំងឡាយ ដែលខ្ញុំបានប្រាប់លោកពីមុនៗមក ហើយបើលោកនៅតែទទូចមិនព្រមលះបង់សេចក្តីសម្រេចចិត្តរបស់លោកនេះ. ខ្ញុំសុំរំលឹកលោកម្តងទៀតចុះ ។

- ជម្រាបអ្នកបួស. ព្រះអង្គម្ចាស់ប៉ៃវិសទ្រង់ទទូចទទៃ. ខ្ញុំពុំដឹងជាត្រូវដំពាក់គុណអ្នកប៉ុន្មានទេ ដែលអ្នកខំខ្នះខ្នែងជួយរក្សាការពារជីវិតខ្ញុំនេះ ដែលជាជនដែលអ្នកមិនទាំងស្គាល់សោះ ហើយគ្មានទាំងបានធ្វើអ្វីជាអំពើគាប់ប្រសើរសមនឹងត្រូវទទួលចិត្តប្រណីនេះផង ។ ប៉ុន្តែខ្ញុំសូមនិយាយនឹងអ្នកថា មុននឹងខ្ញុំសម្រេចចិត្តយ៉ាងណា. ខ្ញុំត្រូវការទៅឱ្យដល់កន្លែងនោះសិន ខ្ញុំពុំអាចបោះបង់គោលបំណងតែម្តង

បានទេ ។ ដូច្នេះ ខ្ញុំសូមអង្វរអ្នកឱ្យមេត្តាអនុគ្រោះប្រាប់ផ្លូវដល់ខ្ញុំ ដូចជាអ្នកបានធ្វើសេចក្ដីអនុគ្រោះដល់បងខ្ញុំផង ។ ខ្ញុំនឹងប្រហែលជាប្រព្រឹត្តធ្វើតាមព័តិមានអ្នកបានប្រសើរជាងបងខ្ញុំ ។

- ព្រោះខ្ញុំពុំអាចហាមឃាត់លោកដូចម្ដេចបាន, អ្នកបួសពោល, ដើម្បីឱ្យលោកជឿ ហើយយល់ព្រមបោះបង់គំនិត ដែលលោកបានសម្រេចមក, បើសិនជាខ្ញុំកុំមានវ័យចាស់ជរាដូច្នេះ ហើយបើសិនជាខ្ញុំអាចឡើងឈរបាន, នោះខ្ញុំនឹងក្រោកឡើងភ្លាមមួយរំពេច ដើម្បីហុចដុំមូលដែលខ្ញុំមាននេះជូនទៅអ្នកភ្លែត សម្រាប់ឱ្យអ្នកប្រើការធ្វើជាមគ្គុទ្ទេសក៏ ។

ដោយឥតបណ្ដោយឱ្យអ្នកបួសមានប្រសាសន៏ទៅទៀត, ព្រះអង្គម្ចាស់ប៉ែរិសក៏យាងចុះពីខ្នងសេះ ហើយយាងចូលទៅជិតអ្នកបួសៗក៏ថ្វាយដុំមូលមួយ បណ្ដាដុំមូលដែលគាត់នៅមានជាច្រើនទៀតមកព្រះអង្គម្ចាស់ ហើយនិយាយទូលព្រះអង្គពីរបៀបដែលត្រូវប្រើ នឹងកិច្ចដែលត្រូវធ្វើ ដូចជាគាត់បាននិយាយទូលព្រះអង្គម្ចាស់បាម៉ានដូច្នោះដែរ។ ហើយបន្ទាប់ពីគាត់បានរំលឹកព្រះអង្គម្ចាស់កុំឱ្យខ្លាចនឹងសម្រែកដែលព្រះអង្គនឹងបានឮ ហើយឥតឃើញមនុស្ស ទោះជាសម្រែកគំហកកំហែងយ៉ាងណាក៏ដោយ ព្រោះវាគ្មានធ្វើអ្វីបានក្រៅពីរាំងរា កុំឱ្យព្រះអង្គយាងឡើងទៅឃើញទ្រុងនិងសត្វ, អ្នកបួសក៏អនុញ្ញាតឱ្យព្រះអង្គម្ចាស់យាងទៅ ។



ព្រះអង្គម្ចាស់ប៉ែរិសក៏សម្ដែងអំណរគុណដល់អ្នកបួសយាងឡើងគង់លើសេះ, បោះដុំមូលទៅខាងមុខនោះ រួចទ្រង់បរសេះតាមដុំមូលនោះ ។ នៅទីបំផុត ព្រះអង្គម្ចាស់ក៏បានយាងទៅដល់ជើងភ្នំ រួចទ្រង់ឃើញដុំមូលនោះឈប់វិល, ព្រះអង្គក៏យាងចុះពីខ្នងសេះ ។ មុននឹងព្រះអង្គចាប់ឈានជំហានដំបូងឡើងទៅលើភ្នំ ព្រះអង្គទ្រង់គង់ឈរនៅកន្លែងដដែលមួយសន្ទុះ ដើម្បីទ្រង់កត់ត្រាឱ្យចាំនូវបម្រាមទាំងឡាយដែលអ្នកបួសបានប្រាប់ ។ រួចទ្រង់ក៏ខំតាំងចិត្តឱ្យក្លាហានឡើង ទើបយាងឡើងទៅសម្រេចព្រះទ័យថា នឹងទៅដល់កំពូលភ្នំ ។ លុះព្រះអង្គម្ចាស់យាងបានប្រហែលជាប្រាំមួយជំហាន ស្រាប់តែឮសម្លេងមួយលេចចេញមកពីក្រោយព្រះអង្គហាក់ដូចជានៅជិតណាស់ ឮដូចជាមាត់មនុស្សស្រែកជេរដូច្នោះថា “ហៃ្អឈប់សិនអ្នកក្លាហានហួសប្រមាណចាំខ្ញុំធ្វើទណ្ឌកម្មមួយជូនសិន !” ។

កាលបើព្រះអង្គម្ចាស់ ទ្រង់ព្រះសណ្ដាប់ឮនូវការប្រមាថយ៉ាងធ្ងន់ដូច្នេះ, ព្រះអង្គក៏ភ្លេចនូវបម្រាមអ្នកបួស, ព្រះអង្គទ្រង់យកព្រះហស្ដចាប់កាន់កាំបិតស្នៀតទ្រង់ងាកបែរទៅក្រោយដើម្បីសងសឹក, ប៉ុន្តែពេលនោះព្រះអង្គម្ចាស់ព្រមទាំងសេះព្រះអង្គក៏ក្លាយទៅជាថ្មខ្មៅទាំងអស់មួយរំពេច ។

ចាប់តាំងពីពេលព្រះអង្គម្ចាស់ប៉ែរិសបានធ្វើដំណើរចេញទៅ, ព្រះអង្គម្ចាស់ក្សត្រីបារីសាដ ជារាល់ថ្ងៃតែងយកចង្កោមគជ់ ដែលព្រះ

នាងបានទទួលពីព្រះអង្គម្ចាស់ប៉ៃរិសមកពាក់នឹងព្រះហស្ត ហើយកាលបើព្រះនាងគ្មានការអ្វីនឹងបំពេញ. ព្រះនាងតែងយកគជ់នោះមកដាក់រមៀលលេងក្នុងបាតព្រះហស្ត ។ ទោះបីនៅវេលាយប់ក៏ព្រះនាងឥតដែលដាក់ចង្កោមគជ់នោះឆ្ងាយពីព្រះអង្គដែរ ។ នៅវេលាយប់. ព្រះនាងទ្រង់យកចង្កោមគជ់នោះមកពាក់នឹងព្រះសុរង. ហើយនៅវេលាព្រឹក កាលបើព្រះនាងទ្រង់តើនឡើង. ព្រះនាងតែងយកព្រះហស្តទៅស្ទាបមើលដើម្បីចង់ដឹងមើលថា តើគជ់នោះនៅតែរត់តាមគ្នាទេ ។ ទីបំផុត នៅថ្ងៃដែលព្រះអង្គម្ចាស់ប៉ៃរិសត្រូវទទួលវាសនាក្លាយទៅជាថ្មខ្មៅ ដូចជាព្រះអង្គម្ចាស់ព្រះរៀមដែរនោះ ព្រះនាងបានមានព្រះបន្ទូលទៅកាន់ចង្កោមគជ់ ដែលព្រះនាងពាក់នៅនឹងព្រះអង្គនោះ ប៉ុន្តែមួយរំពេចនោះ ព្រះនាងក៏សង្កេតឃើញគជ់ទាំងឡាយឈប់ស្តាប់បង្គាប់ព្រះនាងទៀត ជាសញ្ញាឱ្យដឹងថា ព្រះអង្គម្ចាស់ប៉ៃរិសទ្រង់សោយទីវង្គតយ៉ាងពិតប្រាកដហើយ ។ ដោយហេតុព្រះនាងបានសម្រេចព្រះទ័យទុកជាមុនស្រេចទៅហើយថា កាលបើរឿងដូច្នេះកើតមានឡើង ព្រះនាងនឹងយាងចេញទៅបំពេញកិច្ចនេះដោយខ្លួនឯងផ្ទាល់ម្តង ។ ដូច្នេះព្រះនាងក៏មានសេចក្តីឈឺចាប់ជាខ្លាំង លុះស្អែកឡើងបន្ទាប់ពីបានស្លៀកពាក់ក្លែងព្រះអង្គធ្វើជាមនុស្សប្រុស និងរៀបចំគ្រឿងអាវុធនិងបរិក្ខារផ្សេងៗរួច និងក្រោយពីមានព្រះសវនីយ៍ប្រាប់បរិវារព្រះនាងថា ព្រះនាងនឹងយាងត្រឡប់មកវិញក្នុងពេលពីរបីថ្ងៃ ព្រះនាងក៏ទ្រង់



យាងគង់លើសេះធ្វើដំណើរចេញទៅតាមផ្លូវតែមួយ ដែលព្រះរៀមទាំងពីរមុនបានយាងទៅដែរ ។

ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ. ដែលទ្រង់ធ្លាប់ជិះសេះបរបាញ់ម្រឹគម្រឹគាស្រាប់ ក៏ទ្រាំទ្រនឹងការអស់ព្រះកាយពលបានគ្រាន់បើជាងស្ត្រីភេទឯទៀត ។ លុះយាងធ្វើដំណើរបានគ្រប់ចំនួនថ្ងៃហើយ. ព្រះនាងក៏បានជួបនឹងអ្នកបួសដដែលនោះនៅថ្ងៃទីម្ភៃមួយ ។ កាលបើព្រះនាងបានយាងទៅដល់ជិតគាត់ ព្រះនាងក៏យាងចុះពីខ្នងសេះ ព្រះហស្តម្ខាងកាន់សេះ ហើយយាងចូលទៅគង់ជិតអ្នកបួសគំនាប់គាត់ គួរសមគាត់តាមធម្មតា រួចព្រះនាងត្រាស់សួរទៅគាត់ថា: “អ្នកបួសដ៏ចម្រើន. សូមអ្នកមេត្តាឱ្យខ្ញុំឈប់សម្រាកក្បែរអ្នកបន្តិច ហើយសូមអ្នកមេត្តានិយាយប្រាប់ខ្ញុំថា តើអ្នកមានបានឮគេនិយាយទេថា នៅទីជិតៗក្នុងភូមិនេះ. មានកន្លែងមួយដែលមានសត្វចេះនិយាយ ដើមឈើចេះច្រៀងនិងទឹកពណ៌លឿង” ។

អ្នកបួសក៏ឆ្លើយថា : “អ្នកស្រី. ដោយហេតុតែសំឡេងអ្នកធ្វើឱ្យខ្ញុំស្គាល់ថា អ្នកជាភេទអ្វីភ្លាម ទោះអ្នកស្រីស្លៀកពាក់ក្លែងក្លាយជាមនុស្សប្រុសក៏ដោយ. បានជាខ្ញុំហៅអ្នកដូច្នេះ ។ ខ្ញុំសូមសម្តែងអំណរគុណនឹងសេចក្តីគួរសមរបស់អ្នកស្រីហើយៗខ្ញុំមានសេចក្តីរីករាយក្រៃលែង ដោយបានទទួលកិត្តិយសបានត្រូវអ្នកស្រីសួរខ្ញុំនេះ ។ ខ្ញុំសូមជម្រាបថា ខ្ញុំស្គាល់ច្បាស់ណាស់កន្លែងដែលអ្នកស្រីសួររកនោះ ប៉ុន្តែតើអ្នកស្រីមានបំណងយ៉ាងណាក្នុងការសួរខ្ញុំនេះ?

- សូមជម្រាបអ្នកបួស, ព្រះអង្គម្ចាស់ក្សត្រីមានព្រះសវនីយ៍, គេបាននិយាយរឿងនេះប្រាប់ខ្ញុំហើយ ខ្ញុំមានសេចក្ដីអន្ទះអន្ទែងចង់បានរបស់នោះជាពន់ប្រមាណ ។

- អ្នកបួសក៏ឆ្លើយថា: "អ្នកស្រី, គេបាននិយាយការពិតជម្រាបអ្នកស្រីមែន, របស់នោះចម្លែកអស្ចារ្យក្រៃលែងដូចគេបានជម្រាប ប៉ុន្តែគេឥតបានជម្រាបអ្នកស្រីទេ អំពីឧបសគ្គទាំងឡាយដែលគេត្រូវពុះពារ ដើម្បីនឹងបានរបស់នោះ ។ បើសិនជាគេបាននិយាយជម្រាបអ្នកស្រីផង ប្រហែលជាអ្នកស្រីមុខជាមិនដាច់ចិត្តចេញធ្វើដំណើរស្វះស្វែងដូច្នេះឡើយ ។ សូមអ្នកស្រីជឿខ្ញុំ ហើយឈប់ប្រាថ្នាយ៉ាងនេះទៅ សូមអញ្ជើញត្រឡប់ទៅវិញ ហើយសូមកុំយល់ថាខ្ញុំនេះធ្វើឱ្យអ្នកស្រីខាតលាភនោះ ។

ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះសវនីយ៍តបថា : "លោកឪពុក, ខ្ញុំមកពីឆ្ងាយណាស់ ហើយខ្ញុំនឹងតូចចិត្តនឹងខ្លួនខ្ញុំជាពុំខាន បើខ្ញុំព្រមត្រឡប់ទៅវិញ ដោយពុំទាន់បានបំពេញកិច្ចតាមបំណង ។ អ្នកបាននិយាយប្រាប់ខ្ញុំ អំពីឧបសគ្គនិងអំពីគ្រោះថ្នាក់បណ្ដាលឱ្យស្លាប់ជីវិត ប៉ុន្តែអ្នកឥតបាននិយាយប្រាប់ខ្ញុំ តើឧបសគ្គនោះយ៉ាងណាខ្លះ ហើយតើគ្រោះថ្នាក់នោះបណ្ដាលមកពីអ្វី ការទាំងនេះហើយដែលខ្ញុំចង់ដឹងណាស់ ដើម្បីខ្ញុំនឹងបានយកទៅពិគ្រោះសួរខ្លួនឯងនិងពិចារណាមើលថា តើខ្ញុំត្រូវជឿឬពុំត្រូវជឿលើសេចក្ដីសម្រេចចិត្ត, លើសេចក្ដីក្លាហាន, នឹងលើកម្លាំងរបស់ខ្ញុំ" ។



នៅពេលនោះ, អ្នកបួសក៏និយាយទូលព្រះអង្គម្ចាស់ក្សត្រីអំពីឧបសគ្គដែលត្រូវឡើងឱ្យបានទៅដល់លើកំពូលភ្នំ ដែលជាលំនៅនៃបក្សាចេះនិយាយ ។ កាលបើយកបក្សានោះបានហើយ វានឹងនិយាយប្រាប់អំពីកន្លែងដើមឈើចេះច្រៀង និងទឹកពណ៌លឿង ។ តមកទៀតអ្នកបួសបាននិយាយទូលព្រះនាង អំពីសំឡេងអ៊ូអរសម្លុតគួរឱ្យញាប់ញ័រ សំឡេងនេះលាន់ឮចេញមកពីគ្រប់ទិស តែឥតឃើញតួមនុស្សទេ ។ នៅទីបំផុតអ្នកបួសបានទូលអំពីថ្មខ្មៅៗជាច្រើន ដែលជាវត្ថុតែមួយអាចធ្វើឱ្យព្រះនាងនិងអ្នកឯទៀតភិតភ័យជាខ្លាំង កាលបើព្រះនាងទ្រង់បានជ្រាបថា ដុំថ្មទាំងឡាយនេះគឺជាខ្មោចអ្នកជិះសេះយ៉ាងក្លាហានៗ ដែលបានផ្លាស់ជាតិពីមនុស្សទៅ ដោយហេតុពុំបានប្រតិបត្តិតាមលក្ខខណ្ឌសំខាន់ៗ ដើម្បីឱ្យបានសម្រេចតាមបំណង គឺកុំឱ្យបែរខ្លួនងាកមើលក្រោយមុននឹងយកបានទ្រុងសត្វសិន ។

កាលបើអ្នកបួសនិយាយចប់ហើយ, ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះសវនីយ៍ថា : "បើតាមខ្ញុំបានស្ដាប់សម្ដីរបស់អ្នក ខ្ញុំក៏បានដឹងថាឧបសគ្គធំៗ ដើម្បីចេញទៅប្រតិបត្តិការឱ្យបានសម្រេចនោះ ទីមួយគឺត្រូវឡើងឱ្យបានទៅដល់ទ្រុងសត្វនោះ កុំឱ្យកោតញញើតនឹងសម្រែកអ៊ូអរ ដែលគេបានស្ដាប់ឮតែឥតឃើញតួមនុស្សអ្នកនិយាយ, ទីពីរគឺកុំឱ្យងាកបែរក្រោយ ។ ចំពោះលក្ខខណ្ឌខាងក្រោយនេះ, ខ្ញុំសង្ឃឹមថាខ្ញុំនឹងអាចធ្វើជាចៅហ្វាយលើចិត្តខ្ញុំបានល្មមគ្រប់គ្រាន់ ។ រីឯចំពោះ

លក្ខខណ្ឌទីមួយវិញ ខ្ញុំសូមបញ្ជាក់ថា សម្រែកផ្សេងៗទាំងឡាយ ដូចដែលអ្នកបានពោលបំភ្លឺខ្ញុំនោះ អាចបន្ទាចទោះបីអ្នកអង់អាចយ៉ាងណា ក៏ឱ្យទៅជាខ្លាចបានដែរ ប៉ុន្តែនៅគ្រប់ការចាប់ផ្ដើមធ្វើទាំងឡាយដែលមានការលំបាកនឹងភយន្តរាយ គេឥតហាមឃាត់មិនឱ្យប្រើការប៉ិនប្រសប់ដែលខ្លួនមាននោះទេ ដូច្នេះខ្ញុំសុំសួរអ្នកថា តើក្នុងរឿងដែលខ្ញុំយល់ថាមានប្រយោជន៍នេះ, គេអាចយកការប៉ិនប្រសប់មកប្រើបានទេ?

- តើការប៉ិនប្រសប់ដូចម្ដេចដែលអ្នកចង់យកមកប្រើនេះ? អ្នកបួសសួរ ។

- ខ្ញុំយល់ថា, ព្រះនាងឆ្លើយ, បើសិនជាខ្ញុំយកសំឡីចុកត្រចៀកឱ្យជិត, ត្រចៀកនោះនឹងពុំសូវមានការចាប់អារម្មណ៍ប៉ុន្មាន ទោះបីសម្រែកឮខ្លាំង ហើយគួរឱ្យព្រឺព្រួចយ៉ាងណាក៏ដោយ ។ កាលបើត្រចៀកស្ដាប់ពុំឮហើយ, សម្រែកនោះក៏គ្មានអានុភាពមកលើមនោគតិខ្ញុំប៉ុន្មានដែរ ខួរក្បាលខ្ញុំនឹងបានស្ថិតនៅជាសេរី ប្រយោជន៍កុំឱ្យវង្វេងវង្វាន់ស្មារតីលុះត្រាបាត់ការប្រើវិចារណញ្ញាណនេះ ។

- អ្នកស្រី, អ្នកបួសឆ្លើយ, ចាប់តាំងពីដើមរហូតមកទល់ឥឡូវនេះ មានជនជាច្រើនបានសួរមកខ្ញុំដើម្បីចង់ដឹងផ្លូវដែលអ្នកស្រីបានសួរខ្ញុំនេះ, ប៉ុន្តែខ្ញុំពុំបានដឹងថា តើមានជនណាមួយបានប្រើការប៉ិនប្រសប់ ដែលអ្នកស្រីបាននិយាយប្រាប់ខ្ញុំនោះទេ ការដែលខ្ញុំដឹង គឺថា



គ្មានរណាម្នាក់បានស្នើសួរខ្ញុំដូចជាអ្នកស្រីនេះសោះ ហើយអ្នកទាំងនោះត្រូវស្លាប់តែហោងអស់ ។ បើសិនជាអ្នកស្រីនៅតែទទូចធ្វើតាមបំណងអ្នកស្រីនេះ, នោះអ្នកស្រីអាចធ្វើល្បងមើលទៅ ប៉ុន្តែសូមអ្នកស្រីជ្រាបថា ខ្ញុំមិនមែនដឹកនាំអ្នកស្រីឱ្យទៅរកបាបគ្រោះទេ ។

- លោកឪពុក, ព្រះអង្គម្ចាស់ក្សត្រីមានព្រះសវនីយ៍, គ្មានអ្វីអាចរាំងរាមិនឱ្យខ្ញុំទទូចធ្វើតាមបំណងខ្ញុំនេះទេ? បេះដូងខ្ញុំបាននិយាយប្រាប់ខ្ញុំថា ការប៉ិនប្រសប់អាចជួយឱ្យខ្ញុំសម្រេចការតាមបំណងបាន, ហើយខ្ញុំបានសម្រេចចិត្តជាស្រេចថា នឹងយកការប៉ិនប្រសប់នេះមកប្រើ ។ ដូច្នេះ ខ្ញុំនៅពុំទាន់ស្គាល់តែផ្លូវដែលខ្ញុំត្រូវធ្វើដំណើរទៅទេ ។ គឺជាសេចក្ដីអនុគ្រោះដែលខ្ញុំត្រូវអង្វរសុំពីអ្នក សូមអ្នកមេត្តាប្រាប់ខ្ញុំកុំប្រកែក ។

អ្នកបួសក៏បានក្រើនរំលឹកព្រះអង្គម្ចាស់ក្សត្រីជាលើកក្រោយបង្អស់ សូមឱ្យព្រះនាងទ្រង់ពិគ្រោះនឹងខ្លួនឯងឱ្យមែនទែន ។ លុះអ្នកបួសសង្កេតឃើញថា គាត់ពុំអាចធ្វើឱ្យព្រះអង្គម្ចាស់ក្សត្រីផ្លាស់ប្ដូរព្រះទ័យបាន, គាត់ក៏លូកយកដុំមូលថ្វាយទៅព្រះនាងរួចពោលថា : “សូមអ្នកស្រីយកដុំមូលនេះទៅ, រួចអញ្ជើញឡើងជិះសេះចុះ ហើយកាលបើអ្នកស្រីបោះដុំមូលនេះទៅមុខអ្នកស្រី សូមអ្នកស្រីបរសេះតាមឱ្យជាប់ ដុំមូលនឹងរមៀលរហូតទៅដល់ភ្នំដែលជាកន្លែងដែលអ្នកស្រីត្រូវការរក ហើយជាកន្លែងដែលវាត្រូវឈប់ ។ កាលបើដុំនេះឈប់រមៀល

ហើយ. សូមអ្នកស្រីឈប់នៅត្រង់នោះដែរ អញ្ជើញចុះពីសេះភ្លាម. រួចអញ្ជើញឡើងទៅលើភ្នំទៅ ។ ដូច្នេះ សូមអ្នកស្រីអញ្ជើញចុះ អ្នកស្រីនឹងបានជ្រាបការតទៅទៀត. តែសូមកុំភ្លេចទាញយកប្រយោជន៍ពីការធ្វើដំណើរនេះឱ្យបាន" ។

ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ក្រោយពីបានមានព្រះសវនីយ៍អរគុណនឹងជម្រាបលាអ្នកបួសនោះ ក៏យាងឡើងជិះសេះ បោះដុំមូលនោះទៅមុខ រួចទ្រង់បរសេះតាមផ្លូវដែលដុំមូលបានរមៀល ។ ដុំមូលនោះចេះតែរមៀលឥតឈប់ ។ លុះដល់ទីបំផុត. ដុំមូលនោះក៏បានទៅឈប់នៅជើងភ្នំ ។ ព្រះអង្គម្ចាស់បានយាងចុះពីខ្នងសេះ. ទ្រង់យកសំឡីចុកព្រះកាណ៌ រួចក៏យាងឡើងមួយៗ តាមផ្លូវទៅតាមកំពូលភ្នំដោយសេចក្ដីអង់អាច ។ ព្រះនាងក៏បានឮសូរសម្រែក ប៉ុន្តែ សំឡីអាចធ្វើជាជំនួយដល់ព្រះនាងយ៉ាងសំខាន់ ។ ហើយដរាបណាព្រះនាងបានយាងទៅមុខបន្តិច ដរាបនោះសម្រែកក៏កាន់តែឮខ្លាំង ប៉ុន្តែមិនមែនដល់ទៅជាកើតការរំភើបបណ្ដាលឱ្យព្រះនាងឡប់ស្មារតីនោះទេ។ ព្រះនាងបានទ្រង់ព្រះសណ្ដាប់សម្រែកជេរជាច្រើនយ៉ាង និងការសើចចំអកផ្សេងៗ គួរឱ្យឈឺចាប់ណាស់ ចំពោះភេទជាស្ត្រីដូចព្រះនាងនោះ ប៉ុន្តែព្រះនាងឥតមានញញើតបន្តិច ទ្រង់បែរជាមានព្រះសម្រួល ហើយមានសវនីយ៍តែម្នាក់ឯងថា : "ខ្ញុំឥតខឹងនឹងពាក្យជេរប្រទេចឬពាក្យចំអកឡកឡឺយរបស់អ្នកនេះទេ ។ ចូរអ្នកនិយាយឱ្យអាក្រក់ជាងនេះទៅ



ទៀតទៅ ខ្ញុំក៏ឥតឈឺក្បាលអ្វីឡើយ ហើយអ្នកមិនអាចរាំងរាខ្ញុំមិនឱ្យធ្វើដំណើរតទៅមុខបានទៀតទេ" ។ នៅទីបំផុត. ព្រះនាងក៏ទ្រង់បានយាងឡើងទៅដល់ទីខ្ពស់ ហើយបានឃើញទ្រុងនិងបក្សា ។ ឯបក្សានោះដោយចូលរួមគំនិតនិងសម្រែកបានខំស្រែកសម្លុតព្រះនាងឮសូរសម្លេងលាន់រំពង ទោះបីមានមាឌតូចដូច្នោះក៏ដោយ ។ បក្សានោះស្រែកឱ្យព្រះនាងថា : "ហ៊ៃស្រីឆ្កួត. ថយចេញឱ្យឆាប់ កុំចូលមកជិតឱ្យសោះ !" ។

ព្រះអង្គម្ចាស់ក្សត្រីសប្បាយព្រះទ័យនឹងឃើញវត្ថុនោះ ក៏បោះជំហានយ៉ាងវែងៗ ។ នៅពេលដែលព្រះនាងបានយាងជិតទៅដល់ទីបំផុតនៃបំណងហើយ. ព្រះនាងក៏បានយាងទៅដល់លើខ្នងភ្នំ ដែលមានផែនដីលាតរាបស្មើផង ។ ព្រះនាងទ្រង់រត់យ៉ាងលឿនតម្រង់ទៅទ្រុង ហើយក៏យកព្រះហស្ដដាក់ពីលើទ្រុង មានព្រះសវនីយ៍ទៅកាន់បក្សាថា : "បក្សាខ្ញុំត្រូវការមកយកឯង ហើយឯងមិនត្រូវគេចទៅណាឱ្យសោះ" ។

នៅពេលដែលព្រះអង្គម្ចាស់ក្សត្រី ទាញយកសំឡីចេញពីព្រះកាណ៌. បក្សាក៏និយាយមកកាន់ព្រះនាងថា : "អ្នកស្រីដ៏ក្លាហាន. សូមអ្នកស្រីកុំខឹងនឹងខ្ញុំឱ្យសោះ ចំពោះការដែលខ្ញុំបានចូលរួមនឹងសម្រែកឯទៀត ដែលបានស្រែកជេរអ្នកស្រីជាច្រើនក្រៃលែង ដើម្បីជួយរក្សាសេរីភាពរបស់ខ្ញុំ ។ ពិតមែនតែខ្ញុំជាប់នៅក្នុងទ្រុង. ក៏ខ្ញុំសប្បាយចិត្ត

នឹងវាសនាខ្ញុំណាស់ ប៉ុន្តែដោយខ្ញុំកើតមកសម្រាប់ធ្វើជាទាសាអ្នកណាមួយដែលមកយកទ្រុងនេះបាន។ ដូច្នេះខ្ញុំនេះជាទាសាអ្នកស្រីហើយព្រោះអ្នកស្រីបានដណ្តើមយកខ្ញុំដោយសេចក្តីក្លាហាន និងថ្លៃថ្នូរជាងមនុស្សឯទៀតទាំងអស់ក្នុងលោក ។ ហើយចាប់តាំងពីពេលនេះទៅ ខ្ញុំសូមសម្តែងភក្តីភាពដែលខ្ញុំពុំអាចប្រព្រឹត្តល្មើសបានចំពោះអ្នកស្រី ព្រមទាំងការទទួលខ្លួនធ្វើតាមសេចក្តីបង្គាប់របស់អ្នកស្រីទាំងអស់ ។ ខ្ញុំស្គាល់ហើយថាអ្នកស្រីជានរណា ហើយខ្ញុំនឹងជម្រាបអ្នកស្រីថា អ្នកស្រីឥតស្គាល់ខ្លួនអ្នកស្រីថាជានរណាទេ ។ ប៉ុន្តែថ្ងៃមួយខ្ញុំនឹងជម្រាបអ្នកស្រីឱ្យបានដឹង ហើយខ្ញុំសង្ឃឹមថាអ្នកស្រីនឹងដឹងគុណខ្ញុំជាច្រើនពុំខាន។ ឥឡូវនេះ ដើម្បីជាការចាប់ផ្តើមឱ្យឃើញនូវសញ្ញាស្មោះត្រង់ ដែលខ្ញុំត្រូវមានចំពោះអ្នកស្រី សូមអ្នកស្រីប្រាប់ខ្ញុំឱ្យដឹងមក អំពីបំណងអ្នកស្រីយ៉ាងណាខ្លះ. ខ្ញុំប្រុងខ្លួនតែនឹងធ្វើជូនហើយ” ។

ព្រះអង្គម្ចាស់ក្សត្រី ពោរពេញទៅដោយសេចក្ដីសប្បាយរកប្រៀបពុំបាន ក៏មានព្រះសវនីយ៏ទៅកាន់បក្សាថា : “បក្សា, ខ្ញុំប្រាថ្នាចង់បានវត្ថុច្រើនណាស់ដែលសុទ្ធតែជារបស់សំខាន់ៗជាទីបំផុត ហើយខ្ញុំមានសេចក្ដីត្រេកអរជាពន់ពេក ដោយបានឮអ្នកសម្ដែងសុឆន្ទៈចំពោះមកខ្ញុំ ។ បក្សា, ជាដំបូង ខ្ញុំបានដឹងថា នៅទីនេះមានទឹកពណ៌លឿងដែលអាចមានគុណភាពយ៉ាងអស្ចារ្យ សូមអ្នកប្រាប់កន្លែងរបស់នេះឱ្យខ្ញុំដឹងមុនរបស់ឯទៀតទាំងអស់” ។ បក្សាក៏ប្រាប់កន្លែងរបស់នោះដល់ព្រះនាង ដែលនៅមិនឆ្ងាយពីទីនោះប៉ុន្មាន ។ ព្រះអង្គម្ចាស់ក្សត្រីក៏យាងទៅកាន់កន្លែងនោះ, ហើយយកដបប្រាក់តូចមួយដែលព្រះនាងបានដាក់ជាប់ទៅជាមួយ ទៅដងទឹកនោះដាក់ពេញ ។ ព្រះនាងក៏យាងត្រឡប់មកកាន់បក្សាវិញ ហើយមានព្រះសវនីយជាថ្មីទៀតថាៈ “បក្សា, ប៉ុណ្ណឹងពុំទាន់គ្រប់គ្រាន់ទេ, ខ្ញុំត្រូវការរកដើមឈើចេះច្រៀងទៀត, ប្រាប់ខ្ញុំមក តើដើមឈើនោះនៅឯណា?” ។ បក្សាក៏ទូលថា : “សូមអ្នកស្រីត្រឡប់ទៅក្រោយ, អ្នកស្រីនឹងឃើញព្រៃឈើមួយ ដែលនៅក្នុងទីនោះមានដើមឈើចេះច្រៀង?” ដោយប្រពៃឈើឥតនៅឆ្ងាយ

ប៉ុន្មានទេ. ព្រះអង្គម្ចាស់ក្សត្រីក៏បានយាងទៅដល់ទីនោះ ហើយក៏ទ្រង់បាន ឮចម្រៀងយ៉ាងពីរោះក៏លេចចេញពីចន្លោះដើមឈើឯទៀត ជាសញ្ញាឱ្យដឹងថាគឺជាដើមឈើដែលព្រះនាងត្រូវការរក ប៉ុន្តែដើមឈើនោះធំហើយខ្ពស់ណាស់ ។ ព្រះនាងក៏ត្រឡប់មកវិញ ហើយមានព្រះសវនីយ៍ទៅកាន់បក្សាថា: "បក្សា. ខ្ញុំបានឃើញដើមឈើចេះច្រៀងហើយ. ប៉ុន្តែខ្ញុំពុំអាចដកឬយកមកបាន" ។

- អ្នកស្រីពុំចាំបាច់ដកឫសវាទេ. អ្នកស្រីគ្រាន់តែកាច់យកមែកវាតូចមួយមក ដើម្បីយកទៅដាំក្នុងសួនអ្នកស្រី ។ មែកនេះនឹងដុះចាក់ឫសភ្លាម កាលបើគេដោតវាចូលទៅក្នុងដី ហើយមិនយូរប៉ុន្មាន. អ្នកស្រីនឹងបានឃើញមែកនេះទៅជាដើមឈើមួយដើមយ៉ាងល្អដូចជាដើមឈើដែលអ្នកស្រីទើបតែនឹងបានឃើញនេះដែរ ។

កាលបើព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដបានរបស់ទាំងបីមុខ ដូចដែលស្រីអ្នកកាន់សាសនាអ៊ីស្លាមបាននិយាយទូលព្រះនាង ហើយធ្វើឱ្យព្រះនាងកើតព្រះទ័យចង់បានជាពន់ប្រមាណមកកាន់នៅនឹងព្រះហស្តហើយ. ព្រះនាងក៏មានសវនីយ៍ទៅកាន់បក្សាទៀតថា : "បក្សា. ការដែលអ្នកបានបំពេញបំណងខ្ញុំទាំងប៉ុន្មាននេះ ពុំទាន់គ្រប់គ្រាន់ទេ. អ្នកនេះជាដើមហេតុនៃមរណភាពនៃបងប្រុសខ្ញុំពីរនាក់. ដែលក្លាយទៅជាថ្មខ្មៅទាំងឡាយ ដែលខ្ញុំបានឃើញកាលពេលខ្ញុំឡើងមក ។ ខ្ញុំប្រាថ្នាចង់បានគាត់ត្រឡប់ទៅស្រុកវិញជាមួយនឹងខ្ញុំ" ។



នៅពេលនោះ គេសង្កេតឃើញបក្សាហាក់ដូចជាមិនចង់បំពេញកិច្ចជូនព្រះនាងតាមបំណង ។ វាធ្វើហាក់ដូចជាច្រិមច្រុម ទើបព្រះនាងទ្រង់សួរបញ្ជាក់បន្ថែមថា : "បក្សា. ឯងនឹកឃើញទេថា ឯងទើបនឹងនិយាយប្រាប់ខ្ញុំថា ឯងជាទាសាខ្ញុំ. ដូច្នេះឯងប្រាកដជាទាសាខ្ញុំហើយ។ជីវិតឯងក៏នៅក្នុងអំណាចខ្ញុំដែរ" ។

- ខ្ញុំមិនអាចប្រកែកនឹងការពិតនោះទេ. បក្សាឆ្លើយ ទោះបីការដែលលោកស្រីសុំឱ្យខ្ញុំធ្វើជាការមានឧបសគ្គធំសម្បើមណាស់ក៏ដោយ ក៏ខ្ញុំត្រូវតែធ្វើបំពេញចិត្តអ្នកស្រីឱ្យបានដែរ ។ សូមអ្នកស្រីក្រឡេកមើលជុំវិញទីនេះ ក្រែងអ្នកស្រីបានប្រទះឃើញក្អមទឹកមួយ ។

- ព្រះនាងក៏ឆ្លើយថា ខ្ញុំឃើញក្អមមួយហើយ ។

- សូមអ្នកស្រីយកក្អមនោះមក. បក្សាពោលបន្ថែម ហើយនៅពេលចុះពីខ្នងភ្នំនេះទៅ សូមអ្នកស្រីយកក្អមដែលមានទឹកពេញនេះ ប្រោចទៅលើគ្រប់ថ្មខ្មៅទាំងអស់. គឺជាមធ្យោបាយសម្លាប់រកបងប្រុសអ្នកស្រីទាំងពីរឱ្យបានឃើញដូចចិត្ត ។

ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដក៏យកក្អមទឹក. ទ្រុងនិងបក្សា. ដបទឹកព្រមទាំងដើមឈើយាងចុះមក ។ លុះយាងមកដល់ក្រោម. ព្រះនាងក៏យកក្អមទឹកនោះ ទៅចាក់លើគ្រប់ថ្មខ្មៅទាំងអស់ដែលព្រះនាងបានឃើញ ហើយថ្មខ្មៅនីមួយ។ ក៏បានប្រែក្លាយទៅជាមនុស្សម្នាក់។ដែរ ។ ដោយព្រះនាងឥតមានភ្លេចស្រោចទឹកលើថ្មណាមួយ

សោះឡើយ សេះទាំងឡាយ. ព្រះអង្គម្ចាស់ព្រះរៀមទាំងពីរ និងពួកសេដ្ឋីអភិជនឯទៀតក៏បានរស់ឡើងទាំងអស់ ហើយព្រះនាងក៏បានស្គាល់ព្រះអង្គម្ចាស់បាម៉ាននឹងព្រះអង្គម្ចាស់ប៉ែរិស ។ ព្រះអង្គម្ចាស់ទាំងពីរ ក៏បានស្គាល់ព្រះនាងដែរ ហើយយាងចុះមកឱបព្រះនាងសម្ដែងសេចក្ដីនឹករលឹក ។ ព្រះនាងក៏មានសវនីយ៍សួរថា : "ម្ចាស់ព្រះរៀមជាទីស្នេហា. តើព្រះអង្គធ្វើអ្វីនៅទីនេះ?" ។ ដោយព្រះអង្គម្ចាស់ទាំងពីរបានឆ្លើយថា ព្រះអង្គទើបតែនឹងតើនពីផ្ទំ ព្រះនាងក៏មានសវនីយ៍ឆ្លើយកាត់ឡើងភ្លាមថា : "ចាំ មែនហើយ. តែបើកុំបានម្ចាស់អូនមកជួយយកអាសាទេ ម្ល៉ោះសមម្ចាស់បងប្រហែលពុំទាន់អស់ងុយទេនៅតែផ្ទំទៅទៀតរហូតដល់ថ្ងៃគេជំនុំជម្រះខ្លួន ។ ម្ចាស់ព្រះរៀមឥតទ្រង់បាននឹកឃើញទេឬថា ម្ចាស់ព្រះរៀមយាងមកទីនេះដើម្បីរកបក្សាចេះនិយាយ. ដើមឈើចេះច្រៀងនិងទឹកពណ៌លឿង ហើយលុះយាងមកដល់ទីនេះ ម្ចាស់ព្រះរៀមក៏បានឃើញថ្មខ្មៅជាច្រើនមែនឬទេ? ឥឡូវសូមម្ចាស់ព្រះរៀមក្រឡេកមើល តើមាននៅសល់មួយទេ ។ អស់លោកទាំងឡាយដែលឈរជុំវិញយើងនេះ ពីមុនគឺជាដុំថ្មខ្មៅទាំងនោះ ។ មិនតែប៉ុណ្ណោះសោះ ម្ចាស់ព្រះរៀមដែលបានក្លាយទៅជាថ្មខ្មៅដែរនោះ ឥឡូវបានប្រែជាតិកំណើតមកវិញអស់ហើយ ។ ហេតុនេះបើសិនជាម្ចាស់ព្រះរៀមត្រូវការចង់ជ្រាបថា តើការអស្ចារ្យនោះយ៉ាងណាទៅ នោះម្ចាស់អូនសូមទូលថា គឺដោយសារគុណធម៌នៃទឹកនៅ



ក្នុងក្អមនេះ ដែលខ្ញុំបានយកទៅច្រួចលើថ្មនីមួយៗ ទើបកើតការអស្ចារ្យនេះឡើង ។ ក្អមទឹកនោះម្ចាស់ក្សត្រីបានដាក់ចោលនៅជើងភ្នំ ព្រោះអស់ត្រូវការយកមកប្រើធ្វើអ្វីទៀតហើយ ។ ក្រោយពីបានដណ្ដើមយកបក្សា ដែលម្ចាស់ព្រះរៀមទតឃើញនៅក្នុងទ្រុងនេះ. មកធ្វើជាទាសាកាលណា. ម្ចាស់អូនក៏រកឃើញដើមឈើចេះច្រៀង និងទឹកពណ៌លឿងទៀត ដែលម្ចាស់អូនកាន់នេះ តែម្ចាស់អូនពុំអាចដាច់ចិត្តត្រឡប់ទៅស្រុកវិញ ដោយឥតបាននាំព្រះរៀមទៅជាមួយផង. ទើបម្ចាស់អូនប្រើអំណាចដែលម្ចាស់អូនត្រូវមានទៅលើបក្សានេះ ឱ្យបក្សាប្រាប់មធ្យោបាយ ។ បក្សាក៏បានប្រាប់ម្ចាស់អូនអំពីកន្លែងក្អមទឹក និងអំពីការប្រើប្រាស់ទឹកក្អមនេះ" ។

ព្រះអង្គម្ចាស់បាម៉ាននិងប៉ែរិស កាលបើទ្រង់បានព្រះសណ្ដាប់ព្រះសវនីយ៍ព្រះនាងដូច្នេះហើយ. ក៏ទ្រង់យល់ថា ព្រះអង្គត្រូវជំពាក់គុណព្រះនាងច្រើនណាស់ ។ ចំណែកពួកសេដ្ឋីគហបតីទាំងឡាយ ដែលឈរកកកុញនៅជុំវិញទីនោះ ហើយដែលបានស្ដាប់ឮព្រះរាជសាសន៍ព្រះអង្គម្ចាស់ក្សត្រីដូច្នោះ ក៏បានសម្ដែងអំណរគុណនឹងសេចក្ដីដឹងគុណជាច្រើនបំផុតដល់ព្រះនាង ដែលបានជួយស្រោចស្រង់ខ្លួនឱ្យមានជីវិតរស់ជាមនុស្សឡើងវិញ ដោយប្រកាសខ្លួនទាំងអស់គ្នាធ្វើជាទាសាព្រះនាង ហើយប្រុងខ្លួនតែនឹងធ្វើតាមបង្គាប់ព្រះនាង ឥតមានចិត្តនឹកច្រណែននឹងព្រះនាងដែលដណ្ដើមយកបានរបស់ដែលខ្លួនប្រាថ្នាចង់បានដែរនោះទេ ។

ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះសវនីយ៍ជាថ្មីឡើងទៀតថាៈ "អស់លោកទាំងឡាយ, បើសិនជាអស់លោកបានយកចិត្តទុកដាក់ស្តាប់ខ្ញុំ, នោះអស់លោកអាចសង្កេតឃើញថា ខ្ញុំគ្មានបំណងអ្វីដទៃក្រៅអំពីរកបងខ្ញុំឱ្យឃើញនេះទេ, ដូច្នេះ បើសិនជាការនេះមានអត្ថប្រយោជន៍ទៅលើអស់លោកដែរ, អស់លោកក៏ឥតត្រូវជំពាក់គុណខ្ញុំដែរ តែខ្ញុំសូមទទួលយ៉ាងរីករាយនូវសេចក្តីស្មោះត្រង់ ដែលអស់លោកប្រុងនឹងសម្តែងឱ្យឃើញជាក់ច្បាស់ ចំពោះរូបខ្ញុំ ហើយខ្ញុំសូមអរគុណនឹងអស់លោកវិញដែរ ។ មួយចំណែកទៀត, ខ្ញុំយល់ថា ឥឡូវនេះអស់លោកទាំងអស់បានត្រឡប់មកជាមនុស្សសេរី ចាកផុតពីក្តីអភ័ព្វហើយៗ ខ្ញុំក៏សុំចូលរួមសប្បាយជាមួយសុភមង្គលអស់លោក ដែលកើតមានក្នុងពេលជួនគ្នាជាមួយនឹងខ្ញុំនេះ។ ប៉ុន្តែ យើងមិនត្រូវនៅកន្លែងនេះតទៅទៀត ដែលជាកន្លែងគ្មានអ្វីត្រូវការឱ្យយើងឈប់នៅយូរទៀតសោះ។ សូមយើងឡើងជិះសេះត្រឡប់ទៅនគររៀងៗខ្លួនវិញ" ។

ដើម្បីជាគំរូ ព្រះអង្គម្ចាស់ក្សត្រីបានយាងមុនគេទៅ យកសេះនៅកន្លែងដែលព្រះនាងបានលែងចោល ។ មុននឹងព្រះនាងឡើងគង់សេះ, ព្រះអង្គម្ចាស់បាម៉ាន ដោយចង់ជួយសម្រាលព្រះនាង, បានអង្វរព្រះនាងសូមឱ្យព្រះអង្គជួយកាន់ទ្រុងសត្វ ។ ព្រះអង្គម្ចាស់ក្សត្រីក៏មានសវនីយ៍ថា : "ម្ចាស់ព្រះរៀម, បក្សានេះជាទាសាខ្ញុំ, ខ្ញុំចង់កាន់ខ្លួនខ្ញុំផ្ទាល់, ប៉ុន្តែបើព្រះរៀមចង់កាន់មែកឈើនៃដើមឈើចេះច្រៀង,



សូមព្រះរៀមអញ្ជើញយកទៅ។ ប៉ុន្តែសូមព្រះរៀមជួយកាន់ទ្រុងសត្វខ្ញុំបន្តិច, ហើយឱ្យទៅខ្ញុំវិញ នៅពេលខ្ញុំបានឡើងជិះសេះស្រួលបួល" ។ កាលបើព្រះនាងបានឡើងគង់សេះស្រួលបួលហើយៗ ព្រះអង្គម្ចាស់ព្រះរៀមក៏បានថ្វាយទ្រុងសត្វនោះទៅ ព្រះនាងក៏ទ្រង់ងាកតម្រង់ទៅទិស ដែលព្រះអង្គម្ចាស់ប៉ែរិសកំពុងគង់ ហើយមានសវនីយ៍ថាៈ "ម្ចាស់ព្រះរៀមប៉ែរិស, នេះដបដាក់ទឹកពណ៌លឿង ខ្ញុំសូមថ្វាយទុកនឹងព្រះរៀមបើព្រះរៀមមិនមានការលំបាកទេ" ។ ព្រះអង្គម្ចាស់ប៉ែរិសក៏ទទួលយកដបទឹកដោយព្រះទ័យរីករាយ ។

កាលបើព្រះអង្គម្ចាស់បាម៉ាន ព្រះអង្គម្ចាស់ប៉ែរិសមួយអន្លើដោយពួកសេដ្ឋីគហបតី បានឡើងគង់និងជិះសេះគ្រប់គ្នាអស់ហើយ, ព្រះអង្គម្ចាស់ក្សត្រីបង្គង់ចាំឱ្យនរណាម្នាក់បរសេះនាំផ្លូវចេញទៅមុខគេ ។ ព្រះអង្គម្ចាស់ទាំងពីរ ចង់ទុកកិត្តិយសនេះជូនដល់ពួកសេដ្ឋី, ឯពួកសេដ្ឋីវិញក៏ចង់ថ្វាយកិត្តិយសនេះចំពោះព្រះនាង ។ លុះព្រះនាងសង្កេតឃើញថា គ្មានជនណាមួយព្រមបរសេះទៅមុខគេសោះ ព្រោះចង់ទុកកិត្តិយសថ្វាយព្រះនាង, ទើបព្រះនាងមានព្រះសវនីយ៍ទៅកាន់អស់លោកទាំងអស់ថា : "អស់លោកទាំងឡាយ, ខ្ញុំចាំឱ្យអស់លោកទាំងឡាយទៅមុន" ។ ជនម្នាក់ដែលនៅក្បែរព្រះនាងជាងគេក៏ឆ្លើយតាងនាមមិត្តខ្លួនទាំងអស់ថា : "អ្នកស្រី, បន្ទាប់ពីយើងខ្ញុំបានដឹងថាយើងខ្ញុំត្រូវជំពាក់គុណអ្នកស្រីច្រើនណាស់នោះៗ គ្មានកិត្តិយសឯណា

ដែលយើងត្រូវធ្វើចំពោះអ្នកស្រីក្រៅពីពេលនេះទេ. ថ្វីបើអ្នកស្រីមិនព្រមឱ្យធ្វើ យើងខ្ញុំអង្វរអ្នកស្រីសុំដើរដង្ហែតាមក្រោយអ្នកស្រីដែរ” ។

ព្រះអង្គម្ចាស់ក្សត្រីក៏មានសវនីយ៍ថា: “អស់លោកជាទីគោរព. ខ្ញុំមិនសមនឹងទទួលកិត្តិយសដែលអស់លោកបម្រុងនឹងធ្វើចំពោះរូបខ្ញុំនេះទេ. ហើយបើសិនជាខ្ញុំព្រមទទួល ក៏ព្រោះតែអស់លោកប្រាថ្នាឱ្យខ្ញុំទទួលដែរ ។ នៅពេលនោះ. ព្រះនាងក៏បរសេះយាងចេញទៅមុនគេ. ហើយព្រះអង្គម្ចាស់និងអស់លោកឯទៀត ក៏បរសេះតាមក្រោយជាមួយគ្នាឥតគិតប្រកាន់ពីឋានៈអ្វីឡើយ ។ នៅពេលយាងត្រឡប់មកវិញនោះ. ព្រះអង្គម្ចាស់. ព្រះអង្គម្ចាស់ក្សត្រី. អស់លោកទាំងអស់បម្រុងចូលទៅជួបអ្នកបួស ដើម្បីសម្តែងអំណរគុណដល់គាត់ ចំពោះបដិសណ្ឋារកិច្ចដ៏ប្រសើរដែលគាត់បានធ្វើដល់បរជនទាំងឡាយ នឹងចំពោះដំបូន្មានរបស់គាត់ដែលអាចជួយស្រោចស្រង់ជីវិតខ្លួនបាន បើសិនជាខ្លួនព្រមជឿហើយគោរពប្រតិបត្តិធ្វើតាម ប៉ុន្តែគាត់ទទួលអនិច្ចកម្មបាត់ទៅហើយ ហើយគេពុំអាចដឹងបានថា តើគាត់ស្លាប់ដោយជរាភាព ឬក៏គាត់ស្លាប់ពីព្រោះតែគាត់អស់ត្រូវការនឹងនៅចាំបង្ហាញផ្លូវដល់ជនឯទៀត ដែលត្រូវការទៅដណ្តើមយកវត្ថុបីយ៉ាង ដែលព្រះអង្គម្ចាស់ក្សត្រីបារីសាដទើបតែនឹងមានជ័យជំនះ ។

ដូច្នេះ អ្នកដំណើរទាំងឡាយក៏ធ្វើដំណើរតទៅទៀត ប៉ុន្តែចេះតែរលោះគ្នាមួយថ្ងៃបន្តិចៗ ដោយមកពីពួកសេដ្ឋីឬអភិជនទាំងឡាយ



ដែលបានអញ្ជើញមកពីប្រទេសនានា កាលបើធ្វើដំណើរមកដល់ផ្លូវទៅកាន់ប្រទេសខ្លួន ក៏ថ្វាយបង្គំលាព្រះអង្គម្ចាស់ក្សត្រីនឹងព្រះអង្គម្ចាស់ទាំងពីរជាបន្តបន្ទាប់គ្នា ។ ព្រះអង្គម្ចាស់ក្សត្រី. ព្រះអង្គម្ចាស់បាម៉ាននឹងព្រះអង្គម្ចាស់ប៉ែរិស ទ្រង់បានខំធ្វើដំណើរតាមផ្លូវតម្រង់មកគេហស្ថានព្រះអង្គ លុះគ្រាបានដល់ដោយសុវត្ថិភាព ។

ដំបូងបង្អស់ ព្រះអង្គម្ចាស់ក្សត្រីបានដាក់ទ្រុងបក្សានោះនៅក្នុងបន្ទប់ទទួលភ្ញៀវ ដែលយើងបានពោលរួចមកហើយ ។ ដោយហេតុថា. បន្ទប់ទទួលភ្ញៀវបែរមុខទៅទិសសួនច្បារ. កាលបើបក្សានោះស្រែកយំឡើងសត្វឯទៀតដូចជាចាប. ក្រួចអឹត. ពពេច. ដូនតា. ល្វាចេក. ហើយនិងសត្វដទៃទៀតច្រើនរាប់ពុំអស់ បានហើរមកទំយំបន្ទរតាមសម្លេងបក្សាចេះនិយាយ ។ ចំណែកឯមែកឈើវិញ. ព្រះនាងបានឱ្យគេយកទៅដាំនៅចំពោះព្រះភក្ត្រព្រះនាង នៅក្នុងកន្លែងសួនច្បារសម្រាប់ដាំផ្កាឆ្ងាយពីផ្ទះបន្តិច ។ មែកឈើនោះបានដុះចាក់ឫសហើយមិនយូប៉ុន្មានក៏ទៅជាដើមឈើមួយធំ. ដែលមានស្លឹកចេះច្រៀងនិងប្រគុំភ្លេងតន្ត្រីយ៉ាងពិរោះ ដូចជាដើមឈើដែលព្រះនាងបានកាច់មែកយកមកនេះដែរ ។ ចំពោះទឹកពណ៌លឿង. ព្រះនាងបានឱ្យគេរៀបធ្វើអាងមួយនៅកណ្តាលសួនបុប្ផា. កាលបើអាងនោះធ្វើហើយស្រេចព្រះនាងក៏យកទឹកនោះទាំងអស់ចាក់ចូលទៅ ។ មួយរំពេចនោះទឹកក៏រីកទំហំឡើង ។ លុះឡើងមកដល់ជិតមាត់អាងស្រាប់តែលេចជា

កណ្ដាប់ស្រូវមួយ យ៉ាងធំចេញពីចំពាក់កណ្ដាលអាងកម្ពស់ប្រហែលម៉ែត្រជំហាន (០.៣២៤៨ម) ហើយហូរធ្លាក់ចុះមកវិញជានិច្ច ឥតធ្វើឱ្យទឹកអាងនោះហៀរចេញបន្តិចបានឡើយ ។

ដំណឹងនៃវត្ថុអស្ចារ្យនេះបានលេចឮរន្ទឺទៅដល់ទីជិតខាង ហើយដោយហេតុថា ទ្វារផ្ទះក៏ដូចជាទ្វារសួនតែងបើកចំហជានិច្ច, មិនយូរប៉ុន្មានប្រជាជនជាច្រើនកកកុញនៅជិតខាងបានចូលមកមើលត្រៀបត្រា ។ ចំនួនពីរបីថ្ងៃកន្លងមក ព្រះអង្គម្ចាស់បាម៉ាននឹងប៉ែរិស កាលបើព្រះកាយពលស្រួលបួលហើយ, ក៏ចាប់ប្រកបរបររស់នៅតទៅទៀត។ ហើយដោយការបរបាញ់សត្វជាការកំសាន្តធម្មតារបស់ព្រះអង្គម្ចាស់, ព្រះអង្គម្ចាស់ក៏ឡើងគង់សេះ រួចក៏យាងចេញទៅបរបាញ់ជាលើកដំបូងបង្អស់ បន្ទាប់ពីពេលទ្រង់បានយាងត្រឡប់មកពីធ្វើដំណើរផ្សងព្រេងវិញ នៅទីដទៃក្រៅពីទីក្រោលសត្វដែលបិតាចិញ្ចឹមបានធ្វើទុកថ្វាយចម្ងាយប្រហែលពីរបីលីយើ (១លីយើ=៤គ.ម.) ពីគេហស្ថានព្រះអង្គ។ នៅពេលដែលព្រះអង្គម្ចាស់កំពុងតែដេញបាញ់ម្រឹគីម្រិគានោះ, ស្រាប់តែលេចព្រះបាទស៊ុលតង់យាងតម្រង់មកទីនោះ កំពុងតែដេញបាញ់សត្វដែរ។ កាលបើព្រះអង្គម្ចាស់ទាំងពីរទតឃើញថា ព្រះបាទស៊ុលតង់នឹងយាងមកដល់ឆាប់ៗ ព្រោះមានពួកទាហានសេះជាច្រើនបានលេចចេញមកពីគ្រប់ទិស ព្រះអង្គក៏ឈប់បាញ់ ហើយយាងថយចេញពីទីនេះ, ដើម្បីកុំឱ្យជួបព្រះរាជា។ ប៉ុន្តែនៅចំតាមផ្លូវដែលព្រះអង្គម្ចាស់



យាងថយចេញនោះ ព្រះអង្គម្ចាស់ក៏បានជួបនឹងព្រះបាទស៊ុលតង់ ត្រង់កន្លែងមួយយ៉ាងចង្អៀតរកតែគេចថយក្រោយកុំឱ្យព្រះអង្គទតឃើញពុំបាន ។ នៅក្នុងខណៈភ្ញាក់ភាន់ភាំងនោះ ព្រះអង្គម្ចាស់ទាំងពីរមានពេលគ្រប់គ្រាន់តែយាងចុះពីខ្នងសេះ ហើយអោនលុតជង្គង់នៅមុខព្រះបាទស៊ុលតង់, ព្រះនលាដ៏ទៀបទៅនឹងដីគ្មានងើបព្រះសិរសាមើលព្រះអង្គឡើយ ។ ប៉ុន្តែព្រះបាទស៊ុលតង់ទ្រង់សង្កេតឃើញព្រះអង្គម្ចាស់គង់សេះយ៉ាងសម, ស្លៀកពាក់យ៉ាងស្អាតបាក់ ដូចជាជនជាប់ព្រះញាតិវង្សនឹងព្រះរាជវាំង, ក៏ចង់ទតព្រះភក្ត្រព្រះអង្គទាំងពីរ ទើបព្រះអង្គទាញសេះឱ្យឈប់ហើយមានព្រះរាជឱង្ការឱ្យព្រះអង្គម្ចាស់ងើបព្រះភក្ត្រឡើង ។

ព្រះអង្គម្ចាស់ទាំងពីរក៏ទ្រង់ងើបឡើង ហើយគង់ឈរនៅមុខព្រះបាទស៊ុលតង់ ប្រកបដោយទឹកមុខស្រឡះស្រស់ស្រាយនិងឫកពាសុភាពរាបសា ។ ព្រះបាទស៊ុលតង់ទ្រង់សម្លឹងមើលព្រះអង្គម្ចាស់មួយសន្ទុះចាប់តាំងពីព្រះសិរសារហូតដល់ចុងព្រះបាទ ឥតមានព្រះបន្ទូលថាដូចម្ដេចឡើយ ។ បន្ទាប់ពីព្រះអង្គបាននឹកស្ងើចសរសើរអាការៈនិងទឹកព្រះភក្ត្រជាទីរីករាយ នៃព្រះអង្គម្ចាស់ហើយ ព្រះអង្គក៏ទ្រង់ត្រាស់សួរថា តើព្រះអង្គម្ចាស់ទាំងពីរជានរណាហើយនៅឯណា? ។

ព្រះអង្គម្ចាស់បាម៉ានក៏មានព្រះបន្ទូលឡើងថា : "បពិត្រលម្អធូលីព្រះបាទ ទូលព្រះបង្គំយើងខ្ញុំជាបុត្រនាយតម្រួតសួនរបស់ព្រះរាជា

ដែលឥឡូវគាត់ស្លាប់បាត់ទៅហើយ ហើយសព្វថ្ងៃទូលព្រះបង្គំយើងខ្ញុំនៅក្នុងផ្ទះដែលគាត់បានសង់ទុកឱ្យមុនពេលគាត់ស្លាប់បន្តិច ប្រយោជន៏ឱ្យទូលព្រះបង្គំយើងខ្ញុំបានជ្រកនៅបណ្ដោះអាសន្នសិន ទម្រាំទូលព្រះបង្គំយើងខ្ញុំមានវ័យគ្រប់ការល្មមបម្រើព្រះអង្គបាន ហើយនឹងបានចូលសុំការព្រះអង្គធ្វើដើម្បីនឹងចិញ្ចឹមជីវិត កាលបើឱកាសល្អបានផ្ដល់ឱ្យ។

- តាមដែលយើងបានឃើញ ព្រះបាទស៊ុលតង់មានព្រះបន្ទូល, គឺអ្នកទាំងពីរចូលចិត្តបរបាញ់សត្វមែនទេ? ។

- បពិត្រព្រះករុណាថ្លៃវិសេសព្រះអង្គម្ចាស់បាម៉ានមានបន្ទូលគឺជាមុខរបរធម្មតារបស់ទូលព្រះបង្គំ ដូចជាមុខរបរនៃជននៅក្រោមអំណាចព្រះអង្គដែលបានស្ម័គ្រចិត្តចូលកាន់អាវុធនៅក្នុងកងទ័ពព្រះអង្គ ហើយមិនត្រូវធ្វេសប្រហែសនឹងករណីយកិច្ចខ្លួនដូច្នោះដែរ ដើម្បីឱ្យស្របទៅតាមទម្លាប់បុរាណ ក្នុងព្រះរាជអាណាចក្រនេះ" ។ ព្រះបាទស៊ុលតង់ទ្រង់ស្ញប់ស្ញែងនឹងចម្លើយប្រកបដោយគតិបណ្ឌិតនេះ ក៏មានព្រះរាជឱង្ការទៅកាន់ព្រះអង្គម្ចាស់ទាំងពីរថា : "ព្រោះការបរបាញ់នេះជាមុខរបរធម្មតារបស់អ្នកហើយ ខ្ញុំសប្បាយចិត្តនឹងចង់ឃើញអ្នកបាញ់ណាស់ ដូច្នេះចូរអ្នកមកជាមួយខ្ញុំ យើងបើកឱ្យអ្នករើសតាមចិត្តអ្នកស្ម័គ្រ តើអ្នកចូលចិត្តបាញ់សត្វអ្វីជាងគេ" ។

ព្រះអង្គម្ចាស់ក៏យាងឡើងគង់សេះ, បរតាមព្រះបាទស៊ុលតង់។ លុះបរសេះចេញទៅមិនបានឆ្ងាយប៉ុន្មាន ព្រះអង្គម្ចាស់ក៏ស្រាប់តែ



ឃើញសត្វជាច្រើនតែម្ដង ។ ព្រះអង្គម្ចាស់បាម៉ានក៏រើសយកសិង្ហ, ព្រះអង្គម្ចាស់ប៉ែរិសខ្លាឃ្មុំ ។ រួចក៏បំផាយសេះចេញទៅភ្លែតដំណាលគ្នាដោយសេចក្ដីអង់អាច ធ្វើឱ្យព្រះបាទស៊ុលតង់ភ្ញាក់ជាខ្លាំង ។ ព្រះអង្គម្ចាស់បានដេញតាមសត្វរៀងៗព្រះអង្គ ហើយក៏បានចោលលំពែងយ៉ាងត្រង់បំផុតទៅត្រូវមុតជាប់នឹងខ្លួនសត្វទាំងនោះ ។ ព្រះអង្គម្ចាស់បាម៉ានចោលត្រូវសិង្ហព្រះអង្គម្ចាស់ប៉ែរិសត្រូវខ្លាឃ្មុំ ហើយក្រោយបន្តិចមកព្រះបាទស៊ុលតង់ក៏ទ្រង់ទតឃើញសត្វនោះដួលមួយម្ដងៗបោលទៅមុខលែងរួច។ គ្មានទ្រង់ឈប់នៅស្ងៀម, ព្រះអង្គម្ចាស់បាម៉ានក៏ដេញតាមខ្លាឃ្មុំមួយទៀត, ព្រះអង្គម្ចាស់ប៉ែរិសក៏ដេញតាមសិង្ហមួយទៀតដែរ, ហើយមិនយូរប៉ុន្មានព្រះអង្គម្ចាស់ក៏បានចោលលំពែងត្រូវសត្វនោះស្លាប់ផ្ងារជើងទាំងពីរ ។ ព្រះអង្គម្ចាស់បម្រុងនឹងបន្តការបរបាញ់ទៅទៀត តែព្រះបាទស៊ុលតង់មិនទ្រង់អនុញ្ញាត, ព្រះអង្គបានមានព្រះរាជឱង្ការហៅត្រឡប់មកវិញ ។ លុះព្រះអង្គម្ចាស់យាងមកដល់ជិតព្រះអង្គហើយ, ព្រះបាទស៊ុលតង់ក៏មានព្រះបន្ទូលថា: "បើសិនជាខ្ញុំបណ្ដោយឱ្យអ្នកបាញ់តទៅទៀត, អ្នកនឹងបំផ្លាញកន្លែងប្រមាញ់ខ្ញុំខ្ទេចខ្ទីអស់មួយរំពេច ។ ខ្ញុំមិនមែនចង់សំចៃសត្វខ្ញុំទេ តែខ្ញុំមានចិត្តប្រណីខ្លួនអ្នកដែលខ្ញុំត្រូវតែទទួលស្គាល់ក្នុងពេលឥឡូវនេះ" ។

ព្រះបាទស៊ុលតង់ក្ងួរសា ក៏កើតព្រះទ័យទោរទន់ស្រឡាញ់ព្រះអង្គម្ចាស់ទាំងពីរព្រះអង្គនោះជាពន់ប្រមាណ។ ហើយព្រះអង្គក៏អញ្ជើញ

ព្រះអង្គម្ចាស់ឱ្យទៅតាមព្រះអង្គក្នុងពេលឥឡូវនេះ ។ ប៉ុន្តែព្រះអង្គម្ចាស់បាម៉ានទ្រង់មានព្រះបន្ទូលឆ្លើយថា : “បពិត្រលួងធូលីព្រះបាទ, ទូលព្រះបង្គំយើងខ្ញុំមិនសមនឹងទទួលកិត្តិយសដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យព្រះរាជទាននេះទេ ហើយទូលព្រះបង្គំយើងខ្ញុំ សូមអង្វរព្រះអង្គ សូមព្រះរាជទានអនុញ្ញាតកុំឱ្យទូលព្រះបង្គំយើងខ្ញុំទៅតាមព្រះអង្គធ្វើអ្វី” ។

ព្រះបាទស៊ុលតង់ទ្រង់ពុំយល់ថា តើដោយហេតុអ្វីបានជាព្រះអង្គម្ចាស់ទាំងពីរមិនព្រមទទួលសេចក្តីអនុគ្រោះនេះ ទើបព្រះអង្គទ្រង់មានព្រះរាជឱង្ការសួរបង្ខំឱ្យព្រះអង្គម្ចាស់ឆ្លើយបំភ្លឺព្រះអង្គ។ ព្រះអង្គម្ចាស់បាម៉ានក៏មានព្រះបន្ទូលឆ្លើយថា : “បពិត្រព្រះករុណាថ្លៃវិសេស, ទូលព្រះបង្គំយើងខ្ញុំមានប្អូនស្រីមួយជាប្អូនពៅបង្អស់ ។ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាបានរស់នៅជាមួយគ្នាជាប់ជានិច្ច ហើយទូលព្រះបង្គំយើងខ្ញុំពុំដែលទទួលធ្វើ ឬធ្វើអ្វីមុនបានសួរយោបល់នាងឡើយ ចំណែកនាងវិញក៏ដូច្នោះដែរ, នាងពុំដែលហ៊ានសម្រេចធ្វើអ្វីដោយពុំទាន់បានសួរយោបល់ទូលព្រះបង្គំយើងខ្ញុំជាមុនឡើយ” ។

ព្រះបាទស៊ុលតង់ក៏មានព្រះបន្ទូលតបថា : “ខ្ញុំសូមសរសើរជាច្រើនចំពោះការរស់នៅរួមគ្នាជាភាតរភាពនេះ។ ដូច្នេះ សូមអ្នកប្រឹក្សានឹងប្អូនស្រីអ្នកមើល ហើយនៅថ្ងៃស្អែក នៅពេលត្រឡប់មកបរបាញ់ជាមួយខ្ញុំ សូមអ្នកយកចម្លើយនោះមកប្រាប់ខ្ញុំកុំខាន” ។



ព្រះអង្គម្ចាស់ទាំងពីរក៏យាងត្រឡប់ទៅលំនៅវិញ ប៉ុន្តែទាំងពីរព្រះអង្គឥតមាននឹកឃើញ មិនត្រឹមតែពីរឿងដែលព្រះអង្គម្ចាស់បានជួបនឹងព្រះបាទស៊ុលតង់ ហើយបានទទួលកិត្តិយសបរបាញ់ជាមួយព្រះអង្គប៉ុណ្ណោះទេ, ប៉ុន្តែទ្រង់ថែមទាំងភ្លេចពុំបាននិយាយទូលព្រះអង្គម្ចាស់ក្សត្រីអំពីរឿងដែលព្រះបាទស៊ុលតង់បានមានព្រះបន្ទូលជាមួយព្រះអង្គម្ចាស់ ហើយព្រះអង្គទ្រង់មានបំណងនឹងនាំព្រះអង្គម្ចាស់ទៅជាមួយនឹងព្រះអង្គទៀតផង ។ លុះថ្ងៃស្អែកឡើង នៅពេលដែលព្រះអង្គម្ចាស់បានយាងទៅដល់ជិតព្រះអង្គ នៅកន្លែងប្រមាញ់ ព្រះបាទស៊ុលតង់ក៏មានព្រះបន្ទូលសួរថា : “ម្តេចទៅ, អ្នកមាននិយាយប្រាប់ប្អូនស្រីអ្នកទេ? នាងយល់ព្រមឱ្យអ្នកទៅលេងនឹងខ្ញុំទេ?” ។ ព្រះអង្គម្ចាស់ទាំងពីរក៏ងាកមើលព្រះភក្ត្រគ្នាភ្លឺះៗ រួចព្រះអង្គម្ចាស់បាម៉ានក៏មានព្រះបន្ទូលថា: “ទូលព្រះបង្គំយើងខ្ញុំសូមអង្វរព្រះអង្គសូមព្រះរាជទានអភ័យទោស, ប្អូនទូលព្រះបង្គំក្តី ទូលព្រះបង្គំក្តីឥតមាននឹកឃើញរឿងនេះបន្តិចសោះឡើយ ។ ដូច្នេះ ចូរអ្នកនឹកកុំភ្លេចក្នុងថ្ងៃនេះ, ហើយថ្ងៃស្អែកនាំចម្លើយមកប្រាប់ខ្ញុំ. ព្រះបាទស៊ុលតង់មានព្រះបន្ទូល”

ជាលើកទីពីរ, ព្រះអង្គម្ចាស់បានភ្លេចរឿងនេះទៀត ហើយព្រះបាទស៊ុលតង់ក៏ឥតទ្រង់ក្រោធនឹងការធ្វេសប្រហែសនេះដែរ ផ្ទុយទៅវិញព្រះអង្គបានលូកយកដុំមាសបីដុំចេញពីក្នុងថង់ព្រះអង្គ ហើយទ្រង់ដាក់ទៅក្នុងថ្នក់អាវព្រះអង្គម្ចាស់បាម៉ាន ទើបមានព្រះបន្ទូល

ដោយញញឹមថា : “ជុំមូលនេះជួយការពារកុំឱ្យអ្នកភ្លេចរឿងដែលខ្ញុំត្រូវការចង់ដឹងនេះទៀត ។ នៅល្ងាចនេះ ជុំមាសនេះនឹងធ្លាក់ចេញពីខ្សែក្រវាត់អ្នក ហើយឮសូរសម្លេងអាចឱ្យអ្នកនឹកឃើញដល់រឿងនេះភ្លាម ដែលអ្នកពុំបាននឹកឃើញនៅពេលមុន ។

រឿងនេះបានកើតឡើងដូចព្រះបាទស៊ុលតង់ទ្រង់បានព្រមានមែន បើអត់មានជុំមាសបីនេះ. ព្រះអង្គម្ចាស់ទាំងពីរប្រាកដជាភ្លេចមានបន្ទូលពីរឿងខាងលើនេះ ទូលព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដទៀត ។ ជុំមាសបានធ្លាក់ចេញពីខ្សែក្រវាត់ព្រះអង្គម្ចាស់បាម៉ាន នៅពេលដែលព្រះអង្គម្ចាស់ដោះខ្សែក្រវាត់ចេញរៀបនឹងចូលផ្ទំ ។ មួយរំពេចនោះព្រះអង្គម្ចាស់ក៏យាងទៅជួបព្រះអង្គម្ចាស់ប៉ែវិស. រួចយាងទៅកាន់បន្ទប់ព្រះអង្គម្ចាស់ក្សត្រីទាំងពីរព្រះអង្គ ។ ព្រះអង្គម្ចាស់ក្សត្រីក៏ពុំទាន់ផ្ទំនៅឡើយដែរ ។ ព្រះអង្គម្ចាស់ព្រះរៀមក៏មានបន្ទូលសុំទោសព្រះនាងអំពីការដែលទ្រង់មករំខានព្រះនាងក្នុងកាលមិនគួរ រួចក៏មានបន្ទូលអំពីរឿងនោះទូលព្រះនាង និងអំពីពេលបានជួបព្រះបាទស៊ុល-តង់ ។

ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដទ្រង់ភ័យនឹងដំណឹងនេះ ទើបមានព្រះសវនីយ៍ថា : “ការដែលម្ចាស់ព្រះរៀមបានជួបនឹងព្រះបាទស៊ុល-តង់ ជាការមួយសប្បាយហើយប្រកបដោយកិត្តិយសមួយធំណាស់ហើយតទៅមុខ ការជួបនេះរឹតតែបណ្តាលឱ្យព្រះរៀមសប្បាយទៀត ។



ប៉ុន្តែចំពោះខ្ញុំម្ចាស់ជាប្អូន ការជួបនេះជាការនាំឱ្យរំខាន ហើយឱ្យព្រួយចិត្តផង ។ ម្ចាស់អូនយល់ច្បាស់ថា ដោយសារតែសេចក្តីរាប់អានចំពោះម្ចាស់អូនហើយ បានជាព្រះរៀមហ៊ានប្រកែកមិនព្រមធ្វើតាមបំណងព្រះបាទស៊ុលតង់ ។ ខ្ញុំសូមដឹងគុណម្ចាស់បងទាំងពីរដ៏ជ្រាលជ្រៅ ម្ចាស់អូនស្គាល់ច្បាស់ហើយមេត្រីភាពរបស់ម្ចាស់បង ចំពោះមកលើរូបម្ចាស់អូនដូចជាមេត្រីភាពម្ចាស់អូនមានទៅលើម្ចាស់បងដែរ ។ ម្ចាស់ព្រះរៀមសុខចិត្តប្រព្រឹត្តអំពើពុំគួរសម ចំពោះព្រះបាទស៊ុលតង់ ដោយហ៊ានប្រកែកត្រង់ៗនឹងព្រះអង្គ កុំឱ្យតែបាត់ការរស់នៅជាភាតរភាពដែលយើងបានប្តេជ្ញានឹងគ្នាមកហើយ ។ ម្ចាស់ព្រះរៀមបានពិចារណាយ៉ាងត្រូវថា បើសិនជាម្ចាស់ព្រះរៀមបានព្រមទៅជាមួយព្រះអង្គទៅហើយ. នោះម្ចាស់ព្រះរៀមនឹងត្រូវឃ្លាតពីប្អូនបន្តិចម្តងៗ លុះត្រាតែត្រូវទៅនៅបម្រើព្រះអង្គរហូត ។ ប៉ុន្តែម្ចាស់ព្រះរៀមស្មានថា ជាការប្រពៃឬ ដែលយើងហ៊ានប្រកែកជាដាច់ខាត នឹងព្រះរាជបំណងព្រះមហាក្សត្រ? សេចក្តីប្រាថ្នារបស់ព្រះបាទស៊ុលតង់ គឺជាឆន្ទៈទាំងឡាយដែលអាចនាំឱ្យមានគ្រោះ បើសិនជាគេប្រកែកពុំធ្វើតាម ។ ដូច្នេះបើសិនជាម្ចាស់អូននឹងឃាត់ព្រះរៀមកុំឱ្យធ្វើតាមបំណងព្រះអង្គទៅ នោះឃើញថា ម្ចាស់អូននឹងរឹតតែធ្វើឱ្យម្ចាស់ព្រះរៀមទទួលរងគំនុំថ្មីពីព្រះអង្គទៀត ហើយនឹងបណ្តាលឱ្យម្ចាស់អូនវេទនាជាមួយនឹងព្រះរៀមផង ។ ម្ចាស់ព្រះរៀមឃើញទេ តើខ្ញុំមានមនោសញ្ចេតនាយ៉ាងណា ។

ដូច្នេះមុននឹងយើងត្រូវឆ្លើយយ៉ាងណាៗនោះ ត្រូវយើងពិគ្រោះសួរ
បក្សាចេះនិយាយសិន ហើយយើងចាំមើលតើបក្សានឹងឱ្យដំបូន្មាន
យើងយ៉ាងណា បក្សាមានបញ្ញាឈ្លាសវៃ ហើយចេះប្រមាណការអ្វីៗ
ដឹងជាមុន ហើយបក្សាតែងជួយយើងនៅពេលមានការលំបាកផ្សេងៗ
ដែលធ្វើឱ្យយើងទាល់គំនិត"។

ព្រះអង្គម្ចាស់ក្សត្រីក៏យកទ្រុងសត្វចេញមក ហើយបន្ទាប់ពី
ព្រះនាងបានស្នើរឿងនោះដល់បក្សាហើយ នៅចំពោះព្រះភក្ត្រព្រះអង្គ
ម្ចាស់. ព្រះនាងក៏សួរទៅបក្សាថា តើឱ្យព្រះអង្គម្ចាស់ធ្វើយ៉ាងណា នៅ
ក្នុងភាពអល់ឯកនេះ ។ បក្សាក៏ឆ្លើយថា : "ត្រូវតែព្រះអង្គម្ចាស់ព្រះ
រៀម ព្រមទាំងអ្នកស្រីធ្វើស្របតាមឆន្ទៈព្រះបាទស៊ុលតង់ ហើយត្រូវ
សុំយាងព្រះអង្គមកលេងផ្ទះអ្នកស្រីដែរ ។

-ប៉ុន្តែ. បក្សា. (ព្រះនាងមានសវនីយ៍) យើងស្រឡាញ់
បងប្អូនយើងរកអ្វីប្រៀបគ្មាន ។ តើមេត្រីភាពរបស់យើងមិនបែកបាក់
ទេឬដោយដំណើរនេះ ។

-គ្មានអ្វីទាំងអស់. (បក្សាឆ្លើយ) មានរឹតតែពីប្រសើរឡើង។

-ដូច្នេះ. ព្រះបាទស៊ុលតង់នឹងឃើញរូបខ្ញុំហើយ (ព្រះនាងមាន
ព្រះសវនីយ៍)។ បក្សាក៏ឆ្លើយថា ជាការចាំបាច់ត្រូវតែឱ្យព្រះអង្គឃើញ
អ្នកស្រីហើយការទាំងអស់នឹងប្រព្រឹត្តទៅយ៉ាងប្រពៃ ។

នៅថ្ងៃស្អែកឡើង ព្រះអង្គម្ចាស់បាម៉ាននិងប៉ែរិសក៏យាងត្រ-



ឡប់ទៅបរបាញ់សត្វវិញ. ហើយព្រះបាទស៊ុលតង់ក៏ទ្រង់ត្រាស់សួរថា
តើព្រះអង្គម្ចាស់មានបាននឹកឃើញស្នើរឿងនោះ ដល់ព្រះអនុជក្សត្រី
ទេ ។ ព្រះអង្គម្ចាស់បាម៉ានក៏យាងចូលទៅជិតព្រះបាទស៊ុលតង់ ហើយ
មានព្រះបន្ទូលថា: "បពិត្រព្រះករុណាថ្លៃវិសេស. ល្អងធូលីអាចតម្រូវ
រូបទូលព្រះបង្គំយើងខ្ញុំបានតាមព្រះរាជបំណង ហើយទូលព្រះបង្គំយើង
ខ្ញុំបានបម្រុងខ្លួននឹងធ្វើតាមបង្គាប់ព្រះអង្គ ព្រោះថាទូលព្រះបង្គំយើង
ខ្ញុំមិនត្រឹមតែបានទទួលសេចក្តីយល់ព្រម ពីប្អូនស្រីទូលព្រះបង្គំយ៉ាង
ងាយប៉ុណ្ណោះទេ គឺនាងថែមទាំងឱ្យយោបល់ថា ទូលព្រះបង្គំយើងខ្ញុំ
មិនដឹងចាំបាច់សួរយោបល់នាងធ្វើអ្វីទេ ដោយហេតុថារឿងនេះជា
ករណីយកិច្ចរបស់ទូលព្រះបង្គំយើងខ្ញុំ ដែលត្រូវមានចំពោះព្រះអង្គ ។
ដូច្នេះបពិត្រព្រះនរបតីទូលព្រះបង្គំយើងខ្ញុំ សូមព្រះអង្គព្រះរាជទាន
អភ័យទោសដល់ទូលព្រះបង្គំផង ចំពោះរឿងនេះ" ។

ព្រះបាទស៊ុលតង់មានព្រះបន្ទូលឆ្លើយថា : "ការនេះសូមឯងកុំ
ព្រួយឱ្យសោះ. យើងយល់ព្រមយ៉ាងរីករាយបំផុត ហើយយើងសង្ឃឹម
ថា ឯងនឹងត្រូវមានការគួរសមនឹងយើងតែត្រឹមប៉ុណ្ណឹងដដែលបាន
ហើយ" ។ ព្រះអង្គម្ចាស់ទាំងពីរអៀនខ្មាសនឹងសេចក្តីត្រាប្រណីហួស
ប្រមាណនេះ ក៏គ្មានមានព្រះបន្ទូលឆ្លើយយ៉ាងណា ក្រៅពីងក់ព្រះ
សិរសាសម្តែងសេចក្តីគោរពយ៉ាងជ្រាលជ្រៅចំពោះព្រះអង្គ ។

នៅថ្ងៃនោះ ព្រះបាទស៊ុលតង់ទ្រង់ឆាប់ឈប់បរបាញ់ ខុសពី